ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ



# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# ការិយបរិច្ឆេទ២០១៧

លេខៈ ១២

ឆ្នាំ២០១៩

# អារម្ភកថា

ការអនុវត្តថវិកាឆ្នាំ២០១៧ បានរួមចំណែកដល់ការធានានូវនិរន្តរភាព និងកិច្ចដំណើរការជាប្រក្រតីនៃស្ថាប័នរដ្ឋ ការរក្សាបាននូវសន្តិសុខ និងស្ថិរភាពនយោបាយ ក៏ដូចជា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលនាំឱ្យរាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលធំៗ ស្របតាមគោលដៅនៃរបៀបវារៈគោលនយោបាយរបស់ខ្លួន ក្នុងការអភិវឌ្ឍ ប្រទេសជាតិ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ជោគជ័យទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈ កំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណ៧% ការកាត់បន្ថយភាពក្រីក្រមកនៅក្រោម១០% ការសម្រេចបានគោលដៅនៃ សូចនាករសេដ្ឋកិច្ចសង្គមធំៗ ជាពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យអប់រំ និងសុខាភិបាល ព្រមទាំងការ កែលម្អប្រព័ន្ធអភិបាលកិច្ច សមត្ថភាពស្ថាប័ន និងការផ្តល់សេវាសាធារណៈ។ ផ.ស.ស សម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី ១ ៣០៨ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៦ ដល់ ១ ៤២៩ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។ ទន្ទឹមនឹងនេះ អតិផរណាមធ្យមប្រចាំឆ្នាំក្នុងរង្វង់២,៩%ក្នុងឆ្នាំ២០១៧ និងអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំរក្សាបាន ក្នុងកម្រិត ៤ ០៤៥រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០១៧ ត្រូវបានទ្រទ្រង់ដោយវិស័យ សំខាន់ៗបី រួមមាន៖ (១)-វិស័យកសិកម្មសម្រេចបានកំណើន១,៧% (២)-វិស័យឧស្សាហកម្មមានកំណើនថម ថយបន្តិចពី១០,៩% ក្នុងឆ្នាំ២០១៦ មកត្រឹម៩,៨% ក្នុងឆ្នាំ២០១៧ និង(៣)-វិស័យសេវាកម្មក៏សម្រេច បានកំណើនល្អប្រសើរពី៦,៨% ក្នុងឆ្នាំ២០១៦ ដល់៧,០% ក្នុងឆ្នាំ២០១៧។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវ គោលនយោបាយអាទិភាពរបស់ខ្លួនប្រកបដោយជោគជ័យដែលឆ្លុះបញ្ចាំងតាមរយៈ ១-បន្តពង្រឹងយ៉ាងម៉ឺងម៉ាត់ និងដាច់ខាតនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម និងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងភាពសុខដុមរមនា ក្នុងសង្គម ក៏ដូចជាភាពសុខក្សេមក្សាន្តរបស់ប្រជាជន ២-បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកប ដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃ អត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព ៣-បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា និងបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃ កំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន ៤-បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរ៍ ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង១លានរៀលនៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អ ប្រសើរ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ការកែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៥-បន្តកិច្ចខិតខំប្រឹងប្រែង ខ្លាំងក្លាថែមទៀតក្នុងការប្រមូលចំណូល ដើម្បីបន្តសម្រេចបានតាមទិសដៅដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរ ចំណូលរយៈពេលមធ្យម២០១៤-២០១៨ ជាពិសេសគឺរក្សាបានចីរភាពចំណូលជាមួយនឹងកំណើនខ្ពស់ ដូច សម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ៦-ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិ ដើម្បី ទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ និងបង្កើនចំណាយវិនិយោគ ផ្ទាល់ ដោយថវិកាជាតិដើម្បីបង្កើនឯករាជ្យភាពនៃថវិកា និងកាត់បន្ថយជាបណ្តើរៗនូវការពឹងផ្អែកលើហិរញ្ញប្ប ទានក្រៅប្រទេស ៧-បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះ បណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ការលើកកម្ពស់សេវាសុខាភិបាល អាហារូបត្ថម្ភ និងសេវាសន្តិសុខសង្គម ៨-បន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់ គាំទ្រកំណើន និងការអភិវឌ្ឍ ជាពិសេសផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យជាដើម ព្រមជាមួយនឹងការផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងសកម្មភាព

អភិវឌ្ឍន៍វិស័យកសិកម្មដែលមានភាពធន់ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងការផ្ទុះជំងឺ ដើម្បីបញ្ចៀសការខូចខាតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅលើការអភិវឌ្ឍសេដ្ឋកិច្ច ៩-បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេសផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព ១០-បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងវិស័យគាំទ្រ ដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញផលិតផលកសិឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម រួមទាំងបន្តការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ១១-បន្តជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ១២-គាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ២០១៦-២០២០ ១៣-បន្តធានាការអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈកាន់តែស៊ីជម្រៅ និងទទួលបានលទ្ធផលផ្លែផ្កាជាក់ស្តែងកាន់តែច្រើនថែមទៀត រួមទាំងការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ជាពិសេសការលើកកម្ពស់គុណភាព និងពង្រីកការទទួលបានភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជាដើម្បីផ្តល់នូវអត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជន និង១៤-ធានាភាពជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។ ជាសក្ខីភាពនាំមកនូវចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៧ កើនឡើង ១៨,៨% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ ចំណូលសារពើពន្ធកើនឡើង ១៩,០% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ ចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៧ កើនឡើង ២៤,៣២% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ និងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១៧ កើនឡើង ៣១,៣៤% បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ សំដៅបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាលំដាប់។ រីឯចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៧ អនុវត្តបានកើនឡើង ១៨,២% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ ចំណាយថវិការាជធានី ខេត្ត អនុវត្តបានកើនឡើង ២៤,៣៦% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ និងចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានកើនឡើង ២៥,១៣% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានការសន្សំអតិរេកថវិកាថ្នាក់ជាតិចំនួន ១ ៦២៩ ៩៧៣,៨លានរៀល។ ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ បានដើរតួជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, ការបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ, ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងការធានាបាននូវភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវន្តនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការកាត់បន្ថយភាពក្រីក្រ។

ថវិកាឆ្នាំ២០១៧ បានជួយបង្កើនល្បឿននៃការដោះស្រាយបញ្ហា ក៏ដូចជាការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ពិសេសការបន្តតម្លើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការទូទៅ និងការផ្តល់នូវមធ្យោបាយ និងធនធានសមស្របដល់ក្រសួងស្ថាប័ន ដើម្បីចូលរួមលើកកម្ពស់សេវាសាធារណៈ ព្រមទាំងបន្តគាំទ្រការវិនិយោគចាំបាច់នានា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច និងផ្តល់លទ្ធផលជូនប្រជាជនគ្រប់ស្រទាប់វណ្ណៈ។

សរុបមក ថវិកាឆ្នាំ២០១៧ ពិតជាសម្រេចបានល្អប្រសើរ ដូចដែលរាជរដ្ឋាភិបាលបានប្រសិទ្ធនាមថាជា **"ថវិកានៃការប្រមូលផ្តុំកម្លាំង និងធនធាន និងសម្រួចវិធានការគោលនយោបាយ ដើម្បីសម្រេចឱ្យខានតែបាននូវសមិទ្ធផលសំខាន់ៗដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល"**។ ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈ ធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រា៧,0% នាំមកនូវចំណូលមធ្យមសម្រាប់ប្រជាជនម្នាក់ៗ ក្នុងឆ្នាំ២០១៧ កើនឡើងដល់១ ៤២៩ដុល្លារអាមេរិក អត្រាភាពក្រីក្របានធ្លាក់ចុះជាលំដាប់។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះ ជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០១៧ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ចំពោះមុខអាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណៈជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀត ដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

ថ្ងៃ អង្គារ ៩រោច ខែ បុស្ស ឆ្នាំ ច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០១៩

**អគ្គសវនករ**



**សោម គីមសួគ៌**

## មាតិកា


**សេចក្តីសង្ខេប** ........ ១

**១. សេចក្តីផ្តើម** ........ ៤

១.១.លក្ខណៈទូទៅ ........ ៤

១.២.ការអនុវត្ត និងដែនកំណត់សវនកម្ម ........ ៤

១.៣.គោលបំណងនៃការផ្សព្វផ្សាយ ........ ៥

**២. ការគ្រប់គ្រងថវិកា** ........ ៥

២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ........ ៥

២.២.កិច្ចប្រតិបត្តិការថវិកា ........ ៦

**៣. លទ្ធផលសវនកម្ម** ........ ៧

**៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ** ........ ៧

៣.១.១. ការចុះបញ្ជីអាជីវកម្មដ្ឋាន ........ ៧

៣.១.២. ប្រសិទ្ធភាពនៃការធ្វើសវនកម្ម ........ ៨

៣.១.៣. ការកំណត់តម្លៃពិន័យលើម៉ូតូនាំចូលល្មើសច្បាប់មិនត្រឹមត្រូវ ........ ៨

៣.១.៤. ការកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់មិនសមស្រប ........ ៩

៣.១.៥. ការពុំទាន់មានវិធានការសមស្របចំពោះប្រាក់កក់ជំពាក់បែបបទរយៈពេលយូរឆ្នាំ ........ ៩

៣.១.៦. ការផ្តល់ឥណទានមូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍កសិកម្មពុំមានធានារ៉ាប់រងអគ្គីភ័យ ........ ១០

៣.១.៧. ការគ្រប់គ្រងចំណូលពីការជួលទីតាំងពុំទាន់បានពេញលេញ ........ ១១

៣.១.៨. ការខកខានក្នុងការបង់ប្រាក់ពិន័យចំពោះក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មរួចតែមិនបានមកធ្វើការដាក់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ........ ១២

៣.១.៩. ភាពយឺតយ៉ាវក្នុងការទូទាត់បំណុលពីការខ្ចីចំណូលយកទៅចំណាយក្រៅបរិបថថវិកា ........ ១៣

៣.១.១០. ការត្រួតពិនិត្យតាមដានការបង់កម្រៃសេវាស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពុំទាន់បានគ្រប់ចំនួន និងទាន់ពេលវេលា ........ ១៤

៣.១.១១. ការកត់ត្រាចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាចំណូលលើបង្កាន់ដៃបង់ប្រាក់ចំណូលមិនទាន់បានត្រឹមត្រូវ ........ ១៤

៣.១.១២. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ........ ១៥

៣.១.១៣. ការបម្រើសេវាចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ........ ១៦

៣.១.១៤. ការប្រមូលចំណូលលើវិស័យព័ត៌មានពុំអស់លទ្ធភាព ........ ១៧

៣.១.១៥. ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទាន ........ ១៧

៣.១.១៦. ការយកថវិកាចំណាយឆ្នាំ២០១៧មកធ្វើការទូទាត់ប្រតិបត្តិការចំណាយឆ្នាំ២០១៦ ........ ១៨

៣.១.១៧. កង្វះខាតក្នុងការត្រួតពិនិត្យឯកសារតម្រូវរបស់ក្រុមហ៊ុនដែលត្រូវដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម ........ ១៩

៣.១.១៨. ការពុំមានតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ........ ២០

៣.១.១៩. ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ និងសេវា ដែលមានសកម្មភាព

អាជីវកម្មមិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា(ប៉ាតង់) ......................................................................២០
៣.១.២០. ភាពយឺតយ៉ាវក្នុងការអនុវត្តគោលនយោបាយប្រគល់ដីធ្លីរបស់រាជរដ្ឋាភិបាលជូន
អតីតមន្ត្រីសង្គមកិច្ចដែលបានស្នាក់នៅ និងកំពុងកាន់កាប់.............................................២១
៣.១.២១. នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារនៅខ្វះចន្លោះ ...................................................២២
៣.១.២២.ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង.......................................................................................២២
៣.១.២៣.ការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកំណត់.................................................២២
៣.១.២៤.ការពុំបានចែងពីការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅក្នុងកិច្ចសន្យា ..............................២៣
៣.១.២៥.ការពុំបានអនុវត្តគម្រោងលទ្ធកម្ម .........................................................................................២៤
៣.១.២៦.ការចំណាយពុំបានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្ម.......................................................................២៤
៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ .......................................................................................២៥
៣.២.១. ការប្រមូលពន្ធប៉ាតង់..................................................................................................................២៥
៣.២.២. ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ..........................................២៦
៣.២.៣. ការយឺតយ៉ាវក្នុងការប្រគល់ទទួលសំណង់វិនិយោគសម្រាប់អាជីវកម្មភាសុី...............២៧
**៤.ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម**.........................................២៨
៤.១. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នៈ .............២៨
៤.២. ការគ្រប់គ្រងអ្នកជាប់ពន្ធ.............................................................................................................២៨
៤.៣. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ......................................................................២៨
៤.៤. ការបំពេញកាតព្វកិច្ចសារពើពន្ធ ...................................................................................................២៩
៤.៥. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ .....................................................................................២៩
៤.៦. ការប្រើប្រាស់វិក្កយបត្រ ................................................................................................................ ៣០
៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ.............................................................................................. ៣០
៤.៨. ការប្រមូលពន្ធអចលនទ្រព្យ ......................................................................................................... ៣១
៤.៩. ការកត់ត្រាចំណូលថវិការដ្ឋ ......................................................................................................... ៣១
៤.១០.ការទូទាត់ និងការកត់ត្រាចំណាយ ..................................................................................................៣២
៤.១១.ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ..............................................................................៣២
៤.១២.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ ...........................................................................៣៣
៤.១៣.ការធ្វើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.......................................................៣៣
៤.១៤.ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ .......................................................................................៣៣
៤.១៥.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ .................................................................................. ៣៤
**៥.សេចក្តីសន្និដ្ឋាន**............................................................................................................................ ៣៤

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៧

## សេចក្តីសង្ខេប


អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈ ដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០១៧ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

### ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **២១ ៦៤៥ ៩៨០,៧លានរៀល** ស្មើនឹង**២៤,១២%** នៃ ផ.ស.ស គឺបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៧,២%** បានកើនឡើង **១៦,៩%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦។ ចំណូលថវិកាខ្ពស់នេះ គឺជាលទ្ធផលនៃកិច្ចប្រឹងប្រែងយូរឆ្នាំរបស់រាជរដ្ឋាភិបាលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តវិធានការជាក់ស្តែងសំខាន់ៗក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ និងការរួមចំណែកពីសកម្មភាពសវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ ដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការអនុវត្តចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អប្រសើរ តាមរយៈ៖ (១).ការបន្តពង្រឹងជាប្រចាំនូវប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ (២).ការបន្តពង្រឹងប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ (៣).ការបន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយ (៤).ការបន្តធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយ និង(៥).ការបន្តពង្រឹងអភិបាលកិច្ចអង្គភាពគយ។ ការអនុវត្តចំណូលពន្ធដារ សម្រេចបានលទ្ធផលល្អប្រសើរ តាមរយៈការកែលម្អគោលនយោបាយសារពើពន្ធ ពង្រឹងរដ្ឋបាលសារពើពន្ធ និងពង្រឹងអភិបាលកិច្ចល្អ ក្នុងគោលដៅបង្កើនចំណូលពន្ធ ធ្វើឱ្យប្រព័ន្ធពន្ធមានភាពសាមញ្ញ មានសមធម៌ និងយុត្តិធម៌ មានស្ថិរភាព មានតម្លាភាព មានប្រសិទ្ធភាព និងបន្ថយអំពើគេចវេសពន្ធ។ ការអនុវត្តចំណូលមិនមែនសារពើពន្ធក៏បានល្អប្រសើរ តាមរយៈការកែលម្អគោលនយោបាយចំណូលមិនមែនសារពើពន្ធ និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការប្រមូលចំណូល និងតឹងទារបំណុលម៉ឺងម៉ាត់ ដែលធ្វើឱ្យមុខសញ្ញាចំណូលសំខាន់ៗមានការកើនឡើង។ ជាមួយនេះដែរ ដើម្បីជួយសម្រាលដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន រាជរដ្ឋាភិបាលបានលើកលែងការបង់កម្រៃការផ្តល់អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រអាពាហ៍ពិពាហ៍ សំបុត្របញ្ជាក់កំណើត ការធ្វើប័ណ្ណបើកបរទោចក្រយានយន្តដែលមានទំហំស៊ីឡាំងក្រោម១២៥សេសេ ព្រមទាំងមិនយកភាស៊ីចំពោះអ្នកលក់តាមកញ្ចើ ល្អី កញ្ច្រែងនៅតាមផ្សារ។

តាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ ការចុះបញ្ជីអាជីវកម្មដ្ឋាន ប្រសិទ្ធភាពនៃការធ្វើសវនកម្ម ការកំណត់តម្លៃពិន័យលើម៉ូតូនាំចូលល្មើសច្បាប់មិនត្រឹមត្រូវ ការកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់មិនសមស្រប ការពុំទាន់មានវិធានការសមស្របចំពោះប្រាក់កក់ជំពាក់បែបបទរយៈពេលយូរឆ្នាំ ការផ្តល់ឥណទានមូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍កសិកម្មពុំមានធានារ៉ាប់រងអគ្គីភ័យ ការគ្រប់គ្រងចំណូលពីការជួលទីតាំងពុំទាន់បានពេញលេញ ការខកខានក្នុងការបង់ប្រាក់ពិន័យចំពោះក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្មរួចតែមិនបានមកធ្វើការដាក់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ភាពយឺតយ៉ាវក្នុងការទូទាត់បំណុលពីការខ្ចីចំណូលយកទៅចំណាយក្រៅបរិបថថវិកា ការត្រួតពិនិត្យតាមដានការបង់កម្រៃសេវាស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពុំទាន់បានគ្រប់ចំនួន និងទាន់ពេលវេលា ការកត់ត្រាចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាចំណូលលើបង្កាន់ដៃបង់ប្រាក់ចំណូលមិនទាន់បានត្រឹមត្រូវ ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ការបម្រើសេវាចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ការប្រមូលចំណូលលើវិស័យព័ត៌មានពុំអស់លទ្ធភាព ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន ការគ្រប់គ្រងអ្នកជាប់ពន្ធ ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ការបំពេញកាតព្វកិច្ចសារពើពន្ធ របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការប្រមូលពន្ធអចលនទ្រព្យ ការកត់ត្រាចំណូលថវិការដ្ឋ ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ។

ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**២០ ០១៦ ០០៦,៩លានរៀល** ស្មើនឹង **២២,៣០%** នៃផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **២,៦%** ហើយបានកើនឡើង **១៨,២%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៦ ដោយបានបំពេញតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក និងដោះស្រាយបាននូវអាទិភាពគោលនយោបាយថ្មីៗ ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងនោះ រួមមាន៖(១).សម្រេចបានការអនុវត្តគោលនយោបាយតម្លើងបៀវត្សរ៍ជូនមន្ត្រីរាជការ ដោយបានតម្លើងបៀវត្សរ៍មូលដ្ឋានក្នុងអត្រា១២% ចាប់ពីខែមករា ឆ្នាំ២០១៧ តម្លើងប្រាក់បំណាច់មុខងារ ចាប់ពីខែមេសា ឆ្នាំ២០១៧ តម្លើងប្រាក់សោធននិវត្តន៍ជូននិវត្តជន ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា ក៏ត្រូវបានតម្លើងពីចំនួន១៦០ពាន់រៀល ដល់ចំនួន៤០០ពាន់រៀល ព្រមទាំងបានផ្តល់ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ។ ការបើកបៀវត្សរ៍សម្រេចបាននៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ និងធ្វើឡើងតាមរយៈប្រព័ន្ធធនាគារ។ (២).បង្កើននូវប្រសិទ្ធភាពចំណាយតាមរយៈវិធានការបង្កើនប្រសិទ្ធភាពក្នុងការវិភាជ និងក្នុងការពិនិត្យផ្តល់ធានាចំណាយ ដោយធានាបាននូវចំណាយចំមុខសញ្ញា មានភាពចាំបាច់ថ្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា។ (៣).នៅក្នុងវិស័យរដ្ឋបាលទូទៅ ការអនុវត្តចំណាយទាបជាងច្បាប់ហិរញ្ញវត្ថុ។ (៤).វិស័យការពារជាតិអនុវត្តលើសច្បាប់ហិរញ្ញវត្ថុ១% គឺដោយសារការកើនឡើងចំណាយឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី និងបុណ្យភ្ជុំបិណ្ឌ ប្រាក់ឧបត្ថម្ភគោលនយោបាយប្រភេទពីរ។ (៥).ក្នុងវិស័យសង្គមកិច្ច ការអនុវត្តត្រូវបានកែលម្អច្រើន ធៀបនឹងឆ្នាំ២០១៦ ដោយអនុវត្តបាន៩៧.៧% នៃច្បាប់ហិរញ្ញវត្ថុ។(៦).ការអនុវត្តចំណាយក្នុងវិស័យសេដ្ឋកិច្ច បានកែលម្អប្រសើរជាងមុន គឺអនុវត្តបាន៩៧.៤% នៃច្បាប់ហិរញ្ញវត្ថុ។(៧).ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន៩១,៣% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ៖ គម្រោងវិនិយោគក្នុងស្រុកអនុវត្តបាន៩៦,១% នៃច្បាប់ហិរញ្ញវត្ថុ លើកលែងតែការវិនិយោគដោយមូលនិធិទ្រទ្រង់ថវិកាដែលអនុវត្តបានទាប ដោយសារពាក់ព័ន្ធនឹងនីតិវិធីខាងដៃគូអភិវឌ្ឍន៍។ (៨).ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០១៧ រាជរដ្ឋាភិបាលសន្សំសំចៃថវិកាបានចំនួន៩៨,៥ ប៊ីលានរៀល ស្មើនឹង៤.១%

គឺបានលើកកម្ពស់ប្រសិទ្ធភាពចំណាយក្នុងគ្រប់ដំណាក់កាល នៃការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈទាំងផ្នែកចំណាយចរន្ត និងទាំងផ្នែកចំណាយវិនិយោគ។ វិធានការលើកកម្ពស់ប្រសិទ្ធភាពចំណាយមិនត្រឹមតែធ្វើឱ្យមានការសន្សំជាសាច់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យក្រសួង ស្ថាប័នមួយចំនួនកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបានទំនិញ សេវា និងសំណង់ ក្នុងបរិមាណច្រើនជាងមុន និងមានគុណភាពល្អជាងមុន ព្រមទាំងចាយកាន់តែចំទិសដៅដែលបានកំណត់នៅក្នុងអំឡុងពេលរៀបចំថវិកាទៀតផង។ (៩).យន្តការផ្ទេរមុខងារ និងធនធានរបស់រដ្ឋាភិបាលថ្នាក់ជាតិឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈក្រសួងមួយចំនួន កំពុងដំណើរការអនុវត្ត។ (១០).ឱនភាពទូទៅនៃថវិកាត្រូវបានកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨ របស់រាជរដ្ឋាភិបាល ជាពិសេសតាមគោលការណ៍គន្លឹះទាំង៤ គឺ៖ ១.ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន ២.ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ៣.ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពដែលទ្រទ្រង់ចីរភាពកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និង៤.ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា៖ ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទាន ការយកថវិកាចំណាយឆ្នាំ២០១៧ មកធ្វើការទូទាត់ប្រតិបត្តិការចំណាយឆ្នាំ២០១៦ កង្វះខាតក្នុងការត្រួតពិនិត្យឯកសារតម្រូវរបស់ក្រុមហ៊ុនដែលត្រូវដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម ការពុំមានតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ និងសេវា ដែលមានសកម្មភាពអាជីវកម្មមិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា(ប៉ាតង់) ភាពយឺតយ៉ាវក្នុងការអនុវត្តគោលនយោបាយប្រគល់ដីធ្លីរបស់រាជរដ្ឋាភិបាលជូនអតីតមន្ត្រីសង្គមកិច្ចដែលបានស្នាក់នៅ និងកំពុងកាន់កាប់ នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារនៅខ្វះចន្លោះការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកំណត់ ការពុំបានចែងពីការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅក្នុងកិច្ចសន្យា ការពុំបានអនុវត្តគម្រោងលទ្ធកម្ម ការចំណាយពុំបានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្ម ការទូទាត់និងការកត់ត្រាចំណាយ ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់ ការផ្ញើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុបស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន **៤ ២១៩ ៤៨៥,៨** លានរៀល ស្មើនឹង**៩៨,៥%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៤ ២៨៤ ៥៥៧,0**លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន **៦៥ ០៧១,២** លានរៀល។

## ២. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានចំនួន **១ ១៧៩ ១៧២,២** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ចំនួន៨,៧% និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបាន **១ ១៧៧ ០០៩,៤** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ចំនួន៨,៥%។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន **១៥៦ ៩៦៦,២** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ចំនួន៨,២% និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន **១៤៧ ១៥៧,៥** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ

ឆ្នាំ២០១៧ ចំនួន**១,៥%**។ រីឯចំណូលចរិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបាន **៤៦៦ ៧២២,០** លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ចំនួន**២៤,៣%** និងចំណាយចរិការបស់រដ្ឋបាលឃុំ សង្កាត់អនុវត្តបាន **៣៥១ ៦០២,៨** លានរៀល គឺទាបជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ ចំនួន **៦,៣%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ ដូចជា៖ ការប្រមូលពន្ធប៉ាតង់ ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ ការយឺតយ៉ាវក្នុងការប្រគល់ទទួលសំណង់វិនិយោគសម្រាប់អាជីវកម្មភាស៊ី។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញប្រកាស និងសារាចរណែនាំច្រើនរំលឹកជាញឹកញាប់ឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីខេត្ត ធ្វើការផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ ដោយអនុវត្តបានមួយចំនួនធំ និងនៅមានខ្វះខាតមួយចំនួនតូច។ ចំពោះការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិវិញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៧ ទ្រព្យសម្បត្តិរដ្ឋមួយចំនួនតូចនៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

# ១. សេចក្តីផ្តើម

## ១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងធ្វើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

## ១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០១៨ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ ២០១៧ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៧៦ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៧ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៧ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូលចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានី ខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

### ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

*ឯកតា : លានរៀល*

| បរិយាយ | ២០១៧ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូល** | **២០ ១៨៤ ៤៥៧,0** | **២១ ៦៤៥ ៩៨០,៧** | **១០៧,២%** |
| -ចំណូលចរន្ត | ១៥ ៥០១ ៤៦៩,0 | ១៦ ៩៦៦ ៦៨៦,៥ | ១០៩.៥% |
| -ចំណូលមូលធនក្នុងប្រទេស | ១៤៨ ៤៣១,0 | ១៤២ ២៤០,៨ | ៩៥,៨% |
| -ចំណូលមូលនិធិទ្រទ្រង់ថវិកា | ២៥០ 000,0 | ៣១៧ ៥៦៧,៦ | ១២៧,0% |
| -ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៨៤ ៥៥៧,0 | ៤ ២១៩ ៤៨៥,៨ | ៩៨,៥% |
| **II. សរុបចំណាយ** | **២០ ៥៥៥ ៨៥៤,0*** | **២០ ០១៦ ០០៦,៩** | **៩៧,៤%** |
| -ចំណាយចរន្ត | ១៣ ៤២២ ០៨៣,0* | ១៣ ២៣៦ ៦២៨,៨ | ៩៨,៦% |
| -ចំណាយមូលធន | ២ ៨៤៩ ២១៤,0 | ២ ៥៥៩ ៨៩២,៣ | ៨៩,៨% |
| -ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៤ ២៨៤ ៥៥៧,0 | ៤ ២១៩ ៤៨៥,៨ | ៩៨,៥% |

### ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

#### ខ₁/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

*ឯកតា : លានរៀល*

| បរិយាយ | ២០១៧ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១ ០៨៥ ២៣៩,0** | **១ ១៧៩ ១៧២,២** | **១០៨,៧%** |
| -ចំណូលចរន្ត | ៩៥៦ ៥២៩,0 | ១ ០៤៣ ៦២៦,៨ | ១០៩,១% |
| •ចំណូលសារពើពន្ធ | ៩២៦ ៣00,0 | ១ ០០៩ ៥៩៥,៣ | ១០៩,0% |
| •ចំណូលមិនមែនសារពើពន្ធ | ៣0 ២២៩,0 | ៣៤ ០៣១,៥ | ១១២,៦% |
| -ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១២៨ ៧១0,0 | ១៣៥ ៥៤៥,៤ | ១០៥,៣% |
| **II. សរុបចំណាយថវិកា** | **១ ០៨៥ ២៣៩,0** | **១ ១៧៧ ០០៩,៤** | **១០៨,៥%** |
| -ចំណាយចរន្ត | ៨៦៣ ១៨0,0 | ៩៦២ ៤០៥,៥ | ១១១,៥% |
| -ចំណាយមូលធន | ២២២ ០៥៩,0 | ២១៤ ៦០៣,៩ | ៩៦,៦% |

* តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន ៣៧១ ៣៩៧លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨។

## ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

*ឯកតា : លានរៀល*

| បរិយាយ | ២០១៧ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **១៤៥ ០៧២,០** | **១៥៦ ៩៦៦,២** | **១០៨,២%** |
| -ចំណូលចរន្ត (មិនមែនសារពើពន្ធ) | ១០ ៩៩៩,០ | ១២ ៨៧៦,៤ | ១១៧,១% |
| -ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ១៣៤ ០៧៣,០ | ១៤២ ១០៩,០ | ១០៦,០% |
| -អតិរេកឆ្នាំ២០១៦ | | ១ ៩៨០,៨ | |
| **II. សរុបចំណាយថវិកា** | **១៤៥ ០៧២,០** | **១៤៧ ១៥៧,៥** | ១០១,៤% |
| -ចំណាយចរន្ត | ១៤៤ ៩៩៦,០ | ១៤៧ ១៥៧,៥ | ១០១,៥% |
| -ចំណាយមូលធន | ៧៦,០ | ០,០ | |

## ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

*ឯកតា : លានរៀល*

| បរិយាយ | ២០១៧ | | |
|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3 = (2/1)* |
| **I. សរុបចំណូលថវិកា** | **៣៧៥ ៤០៣,០** | **៤៦៦ ៧២២,០** | **១២៤,៣%** |
| -ចំណូលមិនមែនសារពើពន្ធ | ០ | ៥ ៦៥៨,៩ | |
| -ចំណូលឧបត្ថម្ភពីថវិកាជាតិ | ៣៧៥ ៤០៣,០ | ៣៧៥ ៥៤២,៥ | ១០០,០% |
| -អតិរេកឆ្នាំ២០១៦ | ០ | ៨៥ ៥២០,៦ | |
| **II. សរុបចំណាយថវិកា** | **៣៧៥ ៤០៣,០** | **៣៥១ ៦០២,៨** | **៩៣,៧%** |
| -ចំណាយសង្កាត់ចំណុះរាជធានី | ២៥ ៣៦៥,៩ | ២២ ១៩៦,១ | ៨៧,៥% |
| -ចំណាយសង្កាត់ចំណុះក្រុង | ២៩ ៥២៩,៧ | ២៦ ៥៧៣,៧ | ៩០,០% |
| -ចំណាយឃុំ | ៣២០ ៥០៧,៤ | ៣០២ ៨៣៣,០ | ៩៤,៥% |

# ៣. លទ្ធផលសវនកម្ម

## ៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

### ៣.១.១. ការចុះបញ្ជីអាជីវកម្មដ្ឋាន

ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និងផ្តល់សេវាល្អដល់អ្នកជាប់ពន្ធ រដ្ឋបាលសារពើពន្ធបានលើកទឹកចិត្តបុគ្គលទាំងឡាយ ដែលធ្វើអាជីវកម្មឱ្យមកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច។ ប្រសិនបើបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ប៉ុន្តែមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ។ តាមការធ្វើតេស្តអាជីវកម្មដ្ឋានមួយចំនួន ដែលត្រូវចុះបញ្ជីនៅតាមបណ្តាសាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួន ដែលក្រុមការងារអង្កេតតាមដងផ្លូវនៃអគ្គនាយកដ្ឋានពន្ធដារបានផ្តល់ទិន្នន័យជូនសាខាពន្ធដារខណ្ឌ និងខេត្តមួយចំនួន ដើម្បីចុះបញ្ជីពន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជីវកម្មដ្ឋានមួយចំនួន នៅមិនទាន់បានមកចុះបញ្ជីពន្ធនៅឡើយ។

ដោយសារតែបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជីខកខានក្នុងការចុះបញ្ជី វាធ្វើឱ្យរដ្ឋបាលសារពើពន្ធជួបការលំបាកក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធ ប្រមូលពន្ធ និងផ្តល់សេវា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងបន្ថែមទៀតចំពោះអាជីវកម្មដ្ឋានដែលមិនបានមកចុះបញ្ជីពន្ធ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារអង្កេតសហគ្រាសនៅតាមដងផ្លូវ និងបានបញ្ជូនទិន្នន័យពីការអង្កេតសហគ្រាស ដើម្បីជូនទៅសាខាពន្ធដារខេត្ត-ខណ្ឌ និងអង្គភាពពាក់ព័ន្ធចាត់ចែងរៀបចំអញ្ជើញម្ចាស់អាជីវកម្មដ្ឋានដែលមានផលរបរដល់កម្រិតត្រូវជាប់ពន្ធ ដើម្បីមកចុះបញ្ជីពន្ធទៅតាមច្បាប់ស្តីពីសារពើពន្ធ។ ដោយឡែក អាជីវកម្មមួយចំនួនដែលក្រុមការងារអង្កេតសហគ្រាសនៅតាមដងផ្លូវបានបញ្ជូនទិន្នន័យទៅនោះ មានខ្លះក៏មិនមានផលរបរដល់កម្រិតត្រូវជាប់ពន្ធនោះទេ។

អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យមើលវឌ្ឍនភាពបន្តទៀត។

### ៣.១.២. ប្រសិទ្ធភាពនៃការធ្វើសវនកម្ម

ដើម្បីឱ្យការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការប្រើប្រាស់ធនធានសវនករពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានណែនាំឱ្យអង្គភាពពន្ធដារក្រោមឱវាទជ្រើសរើសអ្នកជាប់ពន្ធ ដែលមានហានិភ័យខ្ពស់ជាអាទិភាពសម្រាប់ការធ្វើសវនកម្ម។ តាមការពិនិត្យមើលតារាងលទ្ធផលការងារសវនកម្មប្រចាំឆ្នាំ២០១៧ របស់សាខាពន្ធដារខណ្ឌចំនួន៩ និងខេត្តចំនួន១៤ (ការធ្វើសវនកម្មលើឯកសារនិងមានកម្រិត) អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាពន្ធដារខណ្ឌចំនួន៦ និងខេត្តចំនួន៣ បានធ្វើសវនកម្ម និងកំណត់ពន្ធសូន្យចំនួន ១២៨ សហគ្រាស ក្នុងចំណោមសហគ្រាសចំនួន ១ ៥៣៦ ដែលបានធ្វើសវនកម្ម។ ការកំណត់ពន្ធសូន្យខាងលើដោយសារការកំណត់ហានិភ័យរបស់សហគ្រាសដែលត្រូវធ្វើសវនកម្មពុំទាន់បានល្អ។

ការរៀបចំផែនការសវនកម្មលើអ្នកជាប់ពន្ធមិនទាន់បានល្អ ធ្វើឱ្យអគ្គនាយកដ្ឋានពន្ធដារមិនអាចសម្រេចគោលដៅដែលបានគ្រោងទុក ព្រមទាំងប្រើប្រាស់ធនធានដែលមានកម្រិតមិនមានប្រសិទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានយន្តការបង្កើនប្រសិទ្ធភាពបន្ថែមទៀតចំពោះការធ្វើសវនកម្មលើឯកសារនិងមានកម្រិតនេះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា ការវិភាគហានិភ័យក្នុងការធ្វើសវនកម្មមិនទាន់បានសុក្រិតនៅឡើយដោយពុំទាន់មានព័ត៌មានគ្រប់គ្រាន់ និងអនុវត្តដោយដៃ។

អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យមើលវឌ្ឍនភាពបន្តទៀត។

### ៣.១.៣. ការកំណត់តម្លៃពិន័យលើម៉ូតូនាំចូលល្មើសច្បាប់មិនត្រឹមត្រូវ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការសម្រុះសម្រួលបទល្មើសគយ ដោយបញ្ជាក់ថា រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលដូចតទៅៈប្រធានទីស្នាក់ការគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីមួយលានប្រាំសែន(១.៥០០.០០០)រៀល ប្រធានការិយាល័យ ឬប្រធានសាខាគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីបួនលាន (៤.០០០.០០០)រៀល អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចេញលិខិតស្តីពីការកែសម្រួលតារាងទិន្នន័យតម្លៃគិតពន្ធគយសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញទោចក្រយានយន្តគ្រប់ប្រភេទ ដោយបញ្ជាក់ថា ចំពោះទោចក្រយានយន្តដែលនាំចូលដោយល្មើសច្បាប់តម្លៃគិតពន្ធគយត្រូវបូកបន្ថែម ១០% លើតម្លៃមានចែងក្នុងតារាង។

តាមការធ្វើតេស្តលើកំណត់ហេតុល្មើសច្បាប់គយ នៅសាខាគយ និងរដ្ឋាករខេត្តឧត្តរមានជ័យ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា សាខាគយ និងរដ្ឋាករខេត្តឧត្តរមានជ័យបានធ្វើការកំណត់តម្លៃពិន័យចំពោះម៉ូតូដែលនាំចូលល្មើសច្បាប់គយ ដោយពុំបានបូកតម្លៃបន្ថែម១០%លើតម្លៃចម្លងការទេ។ កត្តានេះនាំឱ្យការកំណត់តម្លៃគិតពន្ធនាំចូលលើទំនិញល្មើសច្បាប់មិនត្រឹមត្រូវ និងនាំឱ្យបាត់បង់ចំណូលពន្ធ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពនិងសូមបំភ្លឺបន្ថែមថា ទោះជាយ៉ាងណាក៏ដោយនេះជាករណីមួយដែលបានកើតឡើងក្នុងឆ្នាំ២០១៧ នៅសាខាគយ និងរដ្ឋាករខេត្តឧត្តរមានជ័យដោយមន្ត្រីគយមានសមត្ថកិច្ចមិនបានបូកបន្ថែម១០%លើតម្លៃគិតពន្ធគយក្នុងតារាងចំពោះករណីទំនិញល្មើសច្បាប់គយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងពិនិត្យមើលនូវវឌ្ឍនភាពបន្តទៀត។

### ៣.១.៤. ការកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់មិនសមស្រប

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានចេញលិខិតស្តីពីការកែសម្រួលតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើមុខទំនិញស្រាបរទេស ត្រូវដាក់ឱ្យអនុវត្តចំពោះទំនិញដែលចូលមកបំពេញបែបបទផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនាំចូល ចាប់ពីថ្ងៃទី០១ខែធ្នូ ឆ្នាំ២០១៧នេះតទៅ។

តាមការធ្វើតេស្តលើកំណត់ហេតុល្មើសច្បាប់គយ និងឯកសារស្នើសុំកំណត់តម្លៃគិតពន្ធលើទំនិញល្មើសច្បាប់គយ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិបានធ្វើការកំណត់តម្លៃលើទំនិញល្មើសច្បាប់គយ ស្រាក្រហមម៉ាក Chateau PavieST.Emilion GrandCRC ២០១៣ ទាបជាងតម្លៃចម្លងការដែលបានចេញឱ្យសម្រាប់អនុវត្តចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ កត្តានេះនាំឱ្យការកំណត់តម្លៃគិតពន្ធនាំចូលមិនសមស្រប និងនាំឱ្យបាត់ចំណូលពន្ធគយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងបំភ្លឺបន្ថែមថា ករណីទំនិញល្មើសប្រភេទស្រាក្រហមChateau Pavie ST.Emilion Grand CRC 2013៖ ការកំណត់តម្លៃលើមុខទំនិញស្រាទាំងនេះគឺជាការភ័ន្តច្រឡំដោយអចេតនារបស់មន្ត្រីគយមានសមត្ថកិច្ច ដែលកើតឡើងដោយសារតម្លៃមុខទំនិញស្រាប្រភេទនេះ ទើបតែត្រូវបានស្រាវជ្រាវ និងដាក់បញ្ចូលក្នុងតារាងទិន្នន័យតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណា ដែលធ្វើឱ្យមន្ត្រីមានសមត្ថកិច្ចខកខានមិនបានផ្ទៀងផ្ទាត់ឱ្យបានគ្រប់ជ្រុងជ្រោយ។ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកត់សម្គាល់ថា ករណីដូចនេះកើតឡើងក្នុងរូបភាពតិចតួចប៉ុណ្ណោះធៀបនឹងទំហំសរុបនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយទាំងមូល។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៥. ការពុំទាន់មានវិធានការសមស្របចំពោះប្រាក់កក់ធំពាក់បែបបទរយៈពេលយូរឆ្នាំ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីនិមុត្តិធានាដោយចែងថា រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានានូវការបង់ពន្ធនិងអាករ ឬដើម្បីធានាថា ប្រតិវេទន៍ករ និង

ភាគីទទួលខុសត្រូវផ្សេងៗទៀត បំពេញនូវកាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងៗទៀត និងប្រការ៩ បានបញ្ជាក់ថា រដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់ រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ។

តាមការធ្វើសវនកម្មនៅសាខាគយ និងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ប្រាក់កក់ដែលមិនទាន់សងបែបបទនៅសាខាគយ និងរដ្ឋាករផែអន្តរជាតិភ្នំពេញគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានទឹកប្រាក់ចំនួន ៤១៧ ៣៤២ ៦៧៨ រៀល និងប្រាក់ដុល្លារចំនួន ៣៦៩ ៨៨២ ដុល្លារ ដែលសល់រយៈពេលយូរឆ្នាំ (ឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១២) មិនទាន់បានសងបែបបទ និងមិនទាន់ឃើញមានវិធានការដោះស្រាយនៅឡើយ។ កត្តានេះនាំឱ្យសមតុល្យគណនីប្រាក់កក់ជារៀល និងប្រាក់ដុល្លារមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំដោយពុំបានជម្រះបញ្ជីបានទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថា តួលេខសមតុល្យប្រាក់កក់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ របស់សាខាគយ និងរដ្ឋាករកំពង់ផែភ្នំពេញពិតជានៅសល់ដូចការលើកឡើងរបស់សវនករមែន។ ករណីនេះអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាសូមធ្វើការបញ្ជាក់ដូចតទៅៈ(១)ការតម្កល់និមុត្តិធានាត្រូវបានកើតឡើងជាប្រចាំទន្ទឹមនឹងការដោះបន្ទុកក៏ត្រូវបានធ្វើជាប្រចាំដោយអនុលោមតាមប្រកាសលេខ ១១២ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីនិមុត្តិធានា។ (២)ដោយឡែកមានករណីខ្លះ និមុត្តិធានាត្រូវបានរក្សាទុកយូរទៅតាមលក្ខខណ្ឌនៃនិមុត្តិធានាដែលមិនតម្រូវឱ្យដកវិញក្នុងរយៈពេលខ្លីទេដូចជា ការតម្កល់និមុត្តិធានាដើម្បីប្រកបធុរកិច្ចជើងសាគយ ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ និងប្រតិបត្តិករទីកន្លែងសន្និធិគយបណ្តោះអាសន្នជាដើម។ (៣)ករណីនិមុត្តិធានាត្រូវបានរក្សាទុកយូរដូចបានលើកឡើងដោយសវនករខាងលើគឺដោយសារម្ចាស់មិនចូលខ្លួនមកដោះបន្ទុក។ ករណីដូចនេះក៏មិនអាចដោះស្រាយរយៈពេលខ្លីបានដែរគឺត្រូវការពេលវេលា ដើម្បីស្រាវជ្រាវរកម្ចាស់មកដោះបន្ទុក ហើយករណីខ្លះត្រូវមានដីកាសម្រេចពីតុលាការទៀតផង។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៦. ការផ្តល់ឥណទានមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍កសិកម្មពុំមានធានារ៉ាប់រងអគ្គីភ័យ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដោយបានបញ្ជាក់ថា នាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុមានភារកិច្ចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍កសិកម្មដោយសហការជាមួយធនាគារអភិវឌ្ឍន៍ជនបទ។

តាមការធ្វើសវនកម្មនៅនាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្នុងឆ្នាំ២០១៧ គណៈកម្មការឥណទាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្មបានពិនិត្យ និងសម្រេចលើសំណើសុំខ្ចីប្រាក់ឥណទានរយៈពេលខ្លី និងរយៈពេលវែងឱ្យដល់សមាគមម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកែច្នៃស្រូវអង្ករ ដោយពុំទាន់ឃើញមានការទិញធានារ៉ាប់រងលើគ្រោះអគ្គីភ័យពីក្រុមហ៊ុនធានារ៉ាប់រងនៅឡើយទេ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបំភ្លឺបន្ថែមថាអតិថិជនដែលទទួលបានហិរញ្ញប្បទានពីមូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្មដោយមិនបានប្រើប្រាស់សេវាធានារ៉ាប់រងដោយសារបញ្ហាចម្បងមួយចំនួនដូចជា៖ (១)ការតម្រូវឱ្យអតិថិជនទិញធានារ៉ាប់រង នឹងធ្វើឱ្យថ្លៃដើមកាន់តែខ្ពស់ក្នុងការទទួលបានឥណទាន (២)ក្រុមហ៊ុនធានារ៉ាប់រងមិនមានគោលនយោបាយក្នុងការផ្តល់សេវាកម្មលើវិស័យកសិកម្ម ជាពិសេសស្រូវ-អង្ករដោយសារមានហានិភ័យខ្ពស់ជាងវិស័យផ្សេងទៀត (៣)ពុំទាន់មានបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងធានារ៉ាប់រងលើវិស័យកសិកម្ម (៤)គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាមួយក្រសួងពាក់ព័ន្ធមួយចំនួនដែលបានបញ្ចូលកម្មវិធី Crop insurance បាននិងងកំពុងសិក្សាជាបណ្តើរៗ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៧. ការគ្រប់គ្រងចំណូលពីការជួលទីតាំងពុំទាន់បានពេញលេញ

ដើម្បីគ្រប់គ្រងការប្រមូលចំណូល និងការពង្រឹងការបង់ចំណូលចូលថវិការដ្ឋឱ្យបានទាន់ពេលវេលាស្របតាមបទបញ្ជាលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រង់ចំណុច១៤ចែងថា " ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការជាមួយក្រសួង-ស្ថាប័នសាមី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការតឹងទារបំណុលផ្នែកឯកជន ឬក្រុមហ៊ុននានាជំពាក់រដ្ឋ ដូចជាៈ បញ្ឈប់ការអនុញ្ញាតនាំចូល-នាំចេញ បង្កកគណនីធនាគារ បញ្ឈប់អាជ្ញាប័ណ្ណ និងក្នុងករណីការអនុវត្តតឹងទារបំណុលនេះមិនមានប្រសិទ្ធភាពក្រសួង-ស្ថាប័នសាមីត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការ" ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៧ ក្រសួងពាណិជ្ជកម្មនៅមានចំណូលពីថ្លៃឈ្នួលជួលអចលនទ្រព្យចំនួន០២កន្លែង ដែលក្រុមហ៊ុនបានបង់ខ្វះ មានទឹកប្រាក់ចំនួន ១៥ ០៨០ ដុល្លារអាមេរិក។

អាស្រ័យហេតុនេះក្រសួងពាណិជ្ជកម្មគួរធ្វើការតាមដាន គ្រប់គ្រង និងទារចំណូលពីថ្លៃឈ្នួលជួលទីតាំងខាងលើឱ្យបានពេញលេញ និងត្រឹមត្រូវ ដើម្បីជៀសវាងខាតបង់ចំណូលចូលថវិការដ្ឋ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថាៈ

- ចំណូលឈ្នួលទីតាំងរោងចក្រអាឈើបឹងសាឡាងមានលម្អៀង៨០ដុល្លារ គឺដោយសារកំណើនថ្លៃឈ្នួលប្រចាំឆ្នាំ។ ប៉ុន្តែទោះជាយ៉ាងណា មន្ត្រីពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្មបាននិងកំពុងទាក់ទងភាគីជួល និងពិនិត្យកិច្ចសន្យានេះឡើងវិញ។

- ចំពោះថ្លៃឈ្នួលស្ថានីយ៍ប្រេងឥន្ធនៈមួយក្នុងក្រុងព្រះសីហនុ យោងលិខិតចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៨ បានកំណត់ថ្លៃឈ្នួលសម្រាប់ឆ្នាំដំបូងចំនួន ១២៥ ០០០ដុល្លារអាមេរិក ដោយគិតចាប់ពីខែកុម្ភៈ ឆ្នាំ១៩៩៨ ដល់ខែមករា ឆ្នាំ១៩៩៩។ ហេតុដូចនេះក្នុងឆ្នាំ២០១៧ ក្រុមហ៊ុនត្រូវបង់ថ្លៃឈ្នួលចំនួន ១២៥ ០០០ ដុល្លារអាមេរិក ហើយរហូតដល់ឆ្នាំ២០១៨ ទើបថ្លៃឈ្នួលទីតាំងនេះត្រូវបង់ចំនួន ១៤០ ០០០ ដុល្លារ ស្របតាមអ្វីដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងក្នុងរបាយការណ៍លទ្ធផលសវនកម្ម។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៨. ការខកខានក្នុងការបង់ប្រាក់ពិន័យចំពោះក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្ម រួចតែមិនបានមកធ្វើការដាក់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ

ដើម្បីគ្រប់គ្រងក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មឱ្យបានពេញលេញ និងត្រឹមត្រូវ ក្រសួងបានចេញប្រកាសលេខ១០៤MOC/SMចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ត្រង់ប្រការ៤បានចែងថា "ក្រុមហ៊ុនទាំងឡាយណាដែលខកខានមិនបានយកប្រតិវេទន៍ប្រចាំឆ្នាំមកតម្កល់ទុកនៅដំណាច់ឆ្នាំនីមួយៗនឹងត្រូវធ្វើការផាកពិន័យសហគ្រាសអាជីវកម្ម។ ប្រាក់ដែលប្រមូលបានពីការផាកពិន័យត្រូវបង់ចូលថវិការដ្ឋ"។ ប្រកាសលេខ ១០៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ត្រង់ប្រការ៥បានចែងថា "ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ទាំងឡាយណា ដែលមានការខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រឹមថ្ងៃផុតកំណត់ នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន១.០០០.០០០រៀល។ ក្នុងករណីក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ដែលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពី១ឆ្នាំឡើងទៅ នឹងត្រូវបង់ប្រាក់ពិន័យ ព្រមទាំងបង់កម្រៃសេវាប្រតិវេទន៍ប្រចាំឆ្នាំទៅតាមចំនួនឆ្នាំដែលខកខាន" និងតារាងឧបសម្ព័ន្ធទី១ភ្ជាប់នឹងប្រកាសរួមលេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រកចុះ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ត្រង់តារាង**ឃ២** ការពិន័យចំពោះការមិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំចំនួន១លានរៀល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៧ មានក្រុមហ៊ុនអាជីវកម្មដែលបានចុះបញ្ជីរួចតែពុំទាន់បានមកធ្វើការតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន និងបង់ប្រាក់ផាកពិន័យចំពោះការខកខានតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំមកក្រសួងពាណិជ្ជកម្មក្នុងឆ្នាំ២០១៧ សរុបមានចំនួន ៦ ១៣៩ ក្រុមហ៊ុនអាជីវកម្ម ដែលមានទឹកប្រាក់ចំនួន ៦ ១៣៩ ០០០ ០០០ រៀល(គិតតាមកម្រៃសេវាសាធារណៈក្នុងឆ្នាំ២០១៧)។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរមានវិធានការឱ្យបានម៉ឺងម៉ាត់ចំពោះក្រុមហ៊ុនអាជីវកម្មដែលមិនព្រមមកធ្វើការតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនមកក្រសួង និងបង់ប្រាក់ផាកពិន័យចូលថវិការដ្ឋឱ្យបានពេញលេញ និងទាន់ពេលវេលា។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថា នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មជាសេនាធិការបានចាត់វិធានការពង្រឹងការបង់ប្រតិវេទន៍ និងការយកពិន័យចំពោះក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មរួច ហើយត្រូវមានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ។ ផែនការដែលនាយកដ្ឋានបានធ្វើគឺបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុន ដែលឱ្យតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈការចេញប្រកាសស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ព្រមទាំងមានការជូនដំណឹងរំលឹកដល់ក្រុមហ៊ុនឱ្យបានដឹងមុនតាមរយៈការផ្ញើ E-mail ចំនួន៤លើកដែលមានរយៈពេល៤ខែ មុនពេលផុតកំណត់។

តាមការពិនិត្យ និងស្រាវជ្រាវ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចាប់ពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរួច ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ២០១៧ មានចំនួនប្រមាណ ៩ ៥១០ ក្រុមហ៊ុន ស្មើនឹង ២៨០,៤% នៃចំនួនជាមធ្យមនៃការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ

នៅមិនទាន់ប្រើប្រាស់ប្រព័ន្ធចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ម្យ៉ាងទៀត ការពិន័យលើការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ បានកើនឡើងពី ០ មុនឆ្នាំ២០១៦ រហូតដល់ប្រមាណ ១ ៣៣៩ ករណីក្នុងឆ្នាំ២០១៧។ ការកើនឡើងនៃការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ និងការពិន័យលើការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំក្នុងឆ្នាំ២០១៧ នេះជាចំណែកជំរុញឱ្យក្រុមហ៊ុនអនុវត្តច្បាប់ និងបំពេញកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែទោះបីជានាយកដ្ឋានបានខិតខំចាត់ផែនការរដ្ឋបាលតាមច្បាប់ និងសិទ្ធិជាមន្ត្រីអនុវត្តច្បាប់យ៉ាងណាក៏ដោយ ក៏នៅមានក្រុមហ៊ុនមួយចំនួនមិនទាន់បានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំនៅឡើយ។ ករណីនេះនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នឹងបន្តជំរុញឱ្យក្រុមហ៊ុនតម្កល់ប្រតិវេទន៍ដែលជាកាតព្វកិច្ចរបស់ក្រុមហ៊ុន។

ដោយឡែក ដើម្បីឱ្យក្រុមហ៊ុនមួយចំនួនដែលខកខានក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ២០១៧ មកបំពេញកាតព្វកិច្ចរបស់ខ្លួន នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមានវិធានការដូចខាងក្រោម៖

- ធ្វើការជូនដំណឹងតាមរយៈសារអេឡិចត្រូនិច(Notification E-mail)
- កំពុងរៀបចំធ្វើការកែសម្រួលឱ្យប្រសើរឡើងនូវ Reporting Tool ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- តម្រូវឱ្យក្រុមហ៊ុនបំពេញកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំមុននឹងធ្វើការចុះបញ្ជីកែប្រែ លុបឈ្មោះក្រុមហ៊ុន និងបង្កើតសាខាផ្សេងៗ
- បន្តធ្វើការផ្សព្វផ្សាយ បណ្តុះបណ្តាលនៅតាមបណ្តារាជធានី-ខេត្តទូទាំងប្រទេស

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.៩. ភាពយឺតយ៉ាវក្នុងការទូទាត់បំណុលពីការខ្ចីចំណូលយកទៅចំណាយក្រៅបរិបថថវិកា

ដើម្បីគ្រប់គ្រងចំណូលថវិការដ្ឋឱ្យបានត្រឹមត្រូវ និងជៀសវាងការដកប្រាក់ចំណូលយកទៅចំណាយខុសគោលការណ៍ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ត្រង់ចំណុចភាគទី៣ និងមាត្រា១០៦ បានចែងថា " ចំណូលថវិកាទាំងអស់ទោះបីស្ថិតក្នុងចំណូលប្រភេទណាក៏ដោយអណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬពន្យារពេលបង់ចូលថវិការដ្ឋដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយឡើយ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងពាណិជ្ជកម្មនៅពុំទាន់បានធ្វើការទូទាត់បំណុលពីការខ្ចីចំណូលយកទៅចំណាយក្រៅបរិបថថវិកាតាំងឆ្នាំ២០០០ ដល់ឆ្នាំ២០០៨សរុបមានចំនួន ១៨៩ ៣៥៦ ២០០ រៀល និង ១៧៤ ៤៤៥ ដុល្លារអាមេរិកនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការដោះស្រាយបំណុលរ៉ាំរ៉ៃពីការខ្ចីចំណូលយកទៅចំណាយពីមុនឱ្យបានទាន់ពេលវេលា និងបង់ចូលថវិការដ្ឋឱ្យគ្រប់ចំនួន។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មសូមទទួលស្គាល់បំណុលខាងលើ ដែលជាបំណុលរ៉ាំរ៉ៃចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៨។ បច្ចុប្បន្ន ក្រសួងពាណិជ្ជកម្ម បាននិងងកំពុងប្រមូលឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីអនុវត្តនីតិវិធីបន្តក្នុងការស្នើសុំលុបបំណុលទាំងនេះចេញពីបញ្ជីបេឡាដោយយោងតាមលិខិតលេខ៩៣៦៨ សហវ.អទច ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១០. ការត្រួតពិនិត្យតាមដានការបង់កម្រៃសេវាស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ពុំទាន់បានគ្រប់ចំនួន និងទាន់ពេលវេលា

តារាងឧបសម្ព័ន្ធទី១ភ្ជាប់នឹងប្រកាសរួមលេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៨៥ សហវ.ប្រកចុះ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ត្រង់ចំណុចV.៤ ចំណុច(ក)លេខ១បានកំណត់ថា "សេវាចេញវិញ្ញាបនបត្រប្រភពដើមទំនិញ(CO)ច្រើនជាង២០០០ ឬស្មើ២០០០PCSត្រូវបង់សេវារដ្ឋបាលចំនួន៥៨ដុល្លារអាមេរិក និងតិចជាង២០០០PCS ត្រូវបង់សេវារដ្ឋបាលចំនួន២៣ដុល្លារអាមេរិក" និងនីតិវិធីនៃដំណើរការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ(CO)តាមប្រព័ន្ធស្វ័យប្រវត្តិរបស់នាយកដ្ឋាននាំចេញ-នាំចូល ក្នុងការផ្តល់សេវាវិញ្ញាបនបត្របញ្ជាក់ពីប្រភពដើមទំនិញនាំចេញ-នាំចូលក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ត្រូវធ្វើការត្រួតពិនិត្យទៅលើការបង់ប្រាក់របស់អ្នកស្នើសុំ(ពិនិត្យ និងផ្ទៀងផ្ទាត់)កម្រៃសេវារដ្ឋបាល ដើម្បីឱ្យអ្នកស្នើសុំបង់ប្រាក់តាមប្រព័ន្ធធនាគារមានភាពត្រឹមត្រូវ និងពេញលេញ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋាននាំចេញ-នាំចូលបានធ្វើការត្រួតពិនិត្យការបង់កម្រៃសេវារដ្ឋបាលក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មមិនទាន់បានត្រឹមត្រូវនៅឡើយ។ តាមការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញជាមួយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុក្នុងប្រព័ន្ធឃើញថា មានការបង់កម្រៃសេវារដ្ឋបាលពីការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញ-នាំចូលរបស់ក្រុមហ៊ុនមិនទាន់គ្រប់ ស្របតាមប្រកាសស្តីពីការកែប្រែកម្រងសេវាសាធារណៈក្នុងឆ្នាំ២០១៧ មានចំនួន១៣០ក្រុមហ៊ុន ដែលមានទឹកប្រាក់ចំនួន១៤ ៦៣៤ ៩១១រៀល។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការណែនាំដល់នាយកដ្ឋាននាំចេញ-នាំចូល ឱ្យធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំពីការគណនាកម្រៃសេវារដ្ឋបាលក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាមួយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដើម្បីឱ្យក្រុមហ៊ុនមកបង់សងឱ្យបានទាន់ពេលវេលា ជៀសវាងការបាត់ចំណូលចូលថវិការដ្ឋជាយថាហេតុ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការបញ្ជាក់ថា ក្រោយពីនាយកដ្ឋាននាំចេញ-នាំចូលបានជូនដំណឹងទៅរោងចក្រដែលបានបង់កម្រៃសេវាមិនទាន់គ្រប់ចំនួនឱ្យមកបង់បន្ថែម តំណាងភាគីរោងចក្របានមកបង់កម្រៃសេវាទាំងអស់នេះរួចរាល់ ស្របទៅតាមកម្រៃដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ១នៃប្រកាសរួមលេខ១៦៤៣ សហវ ប្រក.ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១១. ការកត់ត្រាចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាចំណូលលើបង្កាន់ដៃបង់ប្រាក់ចំណូលមិនទាន់បានត្រឹមត្រូវ

តារាងឧបសម្ព័ន្ធទី១ មាតិកាចំណូលភ្ជាប់ជាមួយប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានកំណត់ពីការកត់ត្រាមាតិកាថវិកានៃគណនីចំណូលដូចខាងក្រោម៖

- គណនី និងអនុគណនី៧៣០២៨ បានកំណត់ពីការកត់ត្រាចំណូលទទួលបានពីការបញ្ជាក់លើហត្ថលេខា លិខិតចំលងច្បាប់ដើម វិញ្ញាបនប័ត្រ លិខិតផ្សេងៗនិងចំណូលពីការអនុញ្ញាត

ផ្សេងៗដល់អ្នកប្រើប្រាស់ដែលបានធានាអះអាងដោយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងចំណូលពីការគ្រប់គ្រងរដ្ឋបាលផ្សេងៗ។

- គណនី និងអនុគណនី៧៣០២៧ បានកំណត់ពីការកត់ត្រាមាតិកាថវិកាគណនីអនុគណនីចំណូលទទួលបានពីការត្រួតពិនិត្យគុណភាពទំនិញ គុណភាពឱសថ កាសែត និងភាពយន្ត និងការគោរពបទដ្ឋាន និងចំណូលពីការពិនិត្យរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន និងការឃ្លាំមើលការអនុវត្តគម្រោង។ ចំណូលទទួលបានពីកម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសាច់សត្វ និងផលិតផលសត្វធ្វើចរាចរ និងនៅសត្តឃាតដ្ឋាន...។ល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាខាកាំកុងត្រូលមួយចំនួនបានប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីប្រមូលចំណូលពីសេវាត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន និងសេវាត្រួតពិនិត្យអនាម័យសត្វ។ ក្នុងបង្កាន់ដៃបង់ប្រាក់ចំណូលនោះតម្រូវឱ្យគណនេយ្យ ឬភ្នាក់ងារប្រមូលចំណូលធ្វើការកត់ត្រាមាតិកាថវិកា (លេខគណនី)ឱ្យបានត្រឹមត្រូវ និងស្របតាមមាតិកាថវិកាទូទៅរបស់រដ្ឋនៅក្នុងបង្កាន់ដៃបង់ប្រាក់ចំណូលសម្រាប់ផ្តល់ជូនអតិថិជន០១ច្បាប់ ០១ច្បាប់ត្រូវភ្ជាប់ជាមួយសំណុំឯកសារ និង០១ច្បាប់ទៀតត្រូវរក្សាទុកដើម្បីធ្វើការតាមដាន និងបូកសរុបចំណូល។ ប៉ុន្តែជាក់ស្តែងឃើញថា បណ្តាសាខាកាំកុងត្រូលមួយចំនួននៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហាវ័ណ-អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) របស់ក្រសួងពាណិជ្ជកម្មបានធ្វើការកត់ត្រាមាតិកាថវិកា (លេខគណនី) នៅក្នុងបង្កាន់ដៃបង់ប្រាក់ចំណូលពុំទាន់បានត្រឹមត្រូវ និងស្របតាមប្រកាសស្តីពីចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការណែនាំដល់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហាវ័ណ-អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ឱ្យធ្វើការណែនាំដល់បណ្តាសាខាកាំកុងត្រូល និងស្នាក់ការកាំកុងត្រូលក្រោមឱវាទឱ្យធ្វើការកត់ត្រាមាតិកាក្នុងបង្កាន់ដៃបង់ប្រាក់ចំណូលជូនអតិថិជនឱ្យបានត្រឹមត្រូវ និងស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មសូមទទួលស្គាល់នូវចំណុចខ្វះចន្លោះនេះ ព្រោះមានការកែសម្រួលមាតិកាថវិកាពីគណនី៧៣២៨ មកគណនី៧៣០២៧ ដោយមន្ត្រីដែលទទួលបន្ទុកកត់ត្រាចំណូលនៃអគ្គនាយកដ្ឋានកាំកុងត្រូលភាគច្រើននៅតាមបណ្តាច្រកព្រំដែន ធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការទទួលព័ត៌មានទាំងនេះ ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏ចំណូលទាំងអស់នេះបានបង់ និងបង្វែរចូលថវិកាជាតិបានគ្រប់ចំនួននិងត្រឹមត្រូវតាមអនុគណនី ដែលបានកំណត់ខាងលើ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១២. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម

ក្រសួងពាណិជ្ជកម្មបានចេញប្រកាសស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ការិយាល័យគ្រប់គ្រងអាជីវកម្មមានភារកិច្ច ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ។ តាមការធ្វើសវនកម្មនៅតាមបណ្តាអង្គភាពមួយចំនួនសម្រាប់ការិយបរិច្ឆេទ ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញដូចខាងក្រោម៖

– មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ បានចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មបានចំនួន៧៨១ ប៉ុន្តែមន្ទីរនៅពុំទាន់ស្រាវជ្រាវកសាងស្ថិតិអាជីវកម្មដ្ឋានទាំងអស់នៅក្នុងខេត្តនៅឡើយ។

– មានមូលដ្ឋានអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មនៅក្នុងខេត្តប៉ៃលិនមានចំនួន ៩៧០ ទីតាំង ប៉ុន្តែមន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិនប្រមូលចំណូលពីការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម បានតែចំនួន ៣៥០ទីតាំងប៉ុណ្ណោះ។

កត្តានេះនាំឱ្យការគ្រប់គ្រងអាជីវកម្មដ្ឋាន និងការប្រមូលចំណូលថវិកានៅពុំទាន់អស់លទ្ធភាព។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលខេត្តប៉ៃលិន សូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការណែនាំដល់មន្ទីរពាណិជ្ជកម្មខេត្តឱ្យអនុវត្តស្របតាមប្រកាសរបស់ក្រសួងឲ្យបានត្រឹមត្រូវ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.១៣. ការបម្រើសេវាចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានកំណត់ប្រកាសរួមលេខ៦៤៨ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រង់ផ្នែក ខ-សេវាសាធារណៈដែលផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត (តារាងឧបសម្ព័ន្ធ) ចំណុច៥-ការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ឬភោគៈ ឬការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬចំណែកភោគៈ (ក្នុង១ក្បាលដី/ប័ណ្ណ) ដែលមានរយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) ១៥ថ្ងៃ។ តាមរយៈការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ មានសំណុំឯកសារស្នើសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិចំនួន ១០០ ឯកសារ ក្នុងចំណោម ២ ៧៩៤ ឯកសារ នៅពេលដែលសំណុំឯកសារស្នើសុំ (បានបង់ពន្ធប្រថាប់ត្រានៅសាខាពន្ធដារខេត្តរួចរាល់ហើយ) មានភាពយឺតយ៉ាវក្នុងការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ក្នុងចន្លោះពី១៥ថ្ងៃ រហូតដល់១០៨ថ្ងៃ (ថ្ងៃធ្វើការ)។

អាស្រ័យហេតុនេះ ដើម្បីអនុវត្តការបម្រើសេវាសាធារណៈឱ្យបានត្រឹមត្រូវ រដ្ឋបាលខេត្តកំពង់ធំគួរណែនាំមន្ទីរខាងលើអនុវត្តឱ្យស្របតាមប្រកាសអន្តរក្រសួងខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ ភាពយឺតយ៉ាវក្នុងការបម្រើសេវាចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ គឺបណ្តាលមកពីប្រជាពលរដ្ឋ ដែលយកឯកសារមកដាក់នៅមន្ទីរមិនមានឯកសារគ្រប់គ្រាន់ ទៅតាមតម្រូវការរបស់មន្ទីរ និងឯកសារមួយចំនួនចាំបាច់ធ្វើការកែតម្រូវ ហើយជួនកាលគាត់យកទៅទុកចោលយូរទើបយកមកឱ្យមន្ទីរវិញ។ រដ្ឋបាលខេត្តកំពង់ធំ សូមឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងធ្វើការណែនាំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំឱ្យអនុវត្តការបម្រើសេវាសាធារណៈឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណែទម្រង់របស់រាជរដ្ឋាភិបាល។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៤. ការប្រមូលចំណូលលើវិស័យព័ត៌មានពុំអស់លទ្ធភាព

ដើម្បីគ្រប់គ្រងការប្រមូលចំណូល ក្រសួងព័ត៌មានបានចេញប្រកាសលេខ១៦៧/០១ ព.ម.ប្រក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរព័ត៌មានខេត្តព្រះវិហារ ត្រង់ប្រការ២ បានចែងថា "មន្ទីរព័ត៌មានខេត្តព្រះវិហារមានភារកិច្ចប្រមូលចំណូលនានាតាមច្បាប់ហិរញ្ញវត្ថុ"។

តាមរយៈការធ្វើសវនកម្មនៅមន្ទីរព័ត៌មានខេត្តព្រះវិហារសម្រាប់ការិយបរិច្ឆេទ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មន្ទីរព័ត៌មានខេត្តព្រះវិហារបានប្រមូលចំណូលលើវិស័យព័ត៌មានបានតែ០១មុខសញ្ញាប៉ុណ្ណោះ គឺការបន្តសុពលភាពអាជីវកម្ម ស្ថានីយ ទូរទស្សន៍ខ្សែកាប ហើយមន្ទីរក៏ពុំទាន់បានស្រង់ស្ថិតិអាជីវកម្មលើវិស័យព័ត៌មាន បោះពុម្ព និងសោតទស្សន៍នៅឡើយ។

ឆ្លើយតបនឹងការលើកឡើងខាងលើ រដ្ឋបាលខេត្តបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ និងជំរុញមន្ទីរព័ត៌មានឱ្យអនុវត្តការងារនេះឱ្យបានល្អប្រសើរ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៥. ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទាន

ដើម្បីសម្រួលដល់ការអនុវត្តកម្មវិធីរបស់ក្រសួងឱ្យបានទាន់ពេលវេលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុញ្ញាតឱ្យក្រសួងបើកប្រាក់យកទៅប្រើប្រាស់ជាមុន រួចក្រសួងត្រូវរួតរះប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ផ្អែកតាមសារាចរណែនាំលេខ００៨ សហវ.អថ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៧ ｌ.គ.អំពីការចំណាយបុរេប្រទានបានណែនាំថា "...ការផ្តល់ប្រាក់បុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ហើយការទូទាត់ប្រាក់បុរេប្រទាននេះ ក៏ត្រូវរួតរះប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧"។ តាមការពិនិត្យមើលតារាងតុល្យភាពគណនីថវិកាសរុបថ្នាក់ជាតិប្រចាំឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានរតនាគារជាតិបានបង្ហាញថា ប្រាក់បុរេប្រទាន ដែលនៅសល់មិនទាន់បានទូទាត់ក្នុងឆ្នាំ២០១៧ មានចំនួន៣៦៣ ៨១៨ ៨៥៩ ៥១១រៀល។

ភាពយឺតយ៉ាវក្នុងការទូទាត់ប្រាក់បុរេប្រទាននាំឱ្យការកត់ត្រាទទួលស្គាល់ប្រតិបត្តិការចំណាយមិនបានពេញលេញតាមឆ្នាំថវិកា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានវិធានការម៉ឺងម៉ាត់ចំពោះក្រសួង ស្ថាប័ន ដែលមិនបានទូទាត់ប្រាក់បុរេប្រទានឱ្យបានទាន់ពេលវេលា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបំភ្លឺបន្ថែមថា សារាចរណែនាំលេខ００៨ សហវ.អថ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាឆ្នាំ២០១៧ គឺបានណែនាំដល់គ្រប់ក្រសួងស្ថាប័ន ឱ្យរួតរះប្រមូលឯកសារសុំទូទាត់ប្រាក់បុរេប្រទានដែលបានចំណាយរួចឱ្យបានមុនថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ហើយបើមិនបានទូទាត់ទាន់ក្នុងឆ្នាំថវិកា២០១៧ទេ គឺនឹងត្រូវកាត់គណនាទានថវិកានៅក្នុងក្របខណ្ឌកញ្ចប់ថវិកាឆ្នាំ២០១៨។ បើទោះបីជាមានការណែនាំយ៉ាងនេះក៏ដោយ ក៏ក្រសួងស្ថាប័នមួយចំនួនដែលបានបុរេប្រទានសាច់ប្រាក់ទៅចំណាយរួចហើយនោះនៅតែមិនរួសរាន់ប្រមូលសក្ខីបត្រចំណាយមកបោះផ្សាយអាណត្តិនិយ័តកម្មជម្រះបញ្ជីបុរេប្រទានជាមួយអគ្គនាយកដ្ឋានរតនាគារជាតិឱ្យបានទាន់ពេលវេលានោះទេ។ ចំពោះបញ្ហាយឺតយ៉ាវក្នុងការទូទាត់បុរេប្រទាននេះ គឺមិនត្រឹមតែមានសារាចរណែនាំស្តីពីការបិទបញ្ជីថវិកាប្រចាំឆ្នាំនីមួយៗ ដើម្បី

ជំរុញពន្លឿនការងារទូទាត់បុរេប្រទាននោះទេ គឺថែមទាំងមានអនុក្រឹត្យលេខ១៥៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ដែលជាវិធានការទប់ស្កាត់ភាពយឺតយ៉ាវក្នុងការទូទាត់បុរេប្រទានផងដែរ។ អគ្គនាយកដ្ឋានរតនាគារជាតិបានរៀបចំលិខិតលេខ៩៤៦៩ អរតន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយភ្ជាប់ជាមួយតារាងរាយលម្អិតសមតុល្យបុរេប្រទានពុំទាន់ទូទាត់ទៅអគ្គនាយកដ្ឋានថវិកា ដើម្បីមានវិធានការបន្ត។ ជាទូទៅ បុរេប្រទានមួយផ្នែកធំ គឺជាចំណាយវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាចំណាយមានចរិតពហុឆ្នាំ ហើយត្រូវធ្វើការទូទាត់ឆ្លងឆ្នាំ ដោយប្រើឥណទានឆ្នាំបន្ទាប់ទៅតាមវឌ្ឍនភាពនៃគម្រោង។ ដូចនេះ បុរេប្រទានចំណាយវិនិយោគ មិនមែនជាចំណាយមិនមានឥណទានទូទាត់នោះទេ គឺបានគ្រោងឥណទានទូទាត់នៅឆ្នាំបន្ទាប់រួចហើយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជំរុញឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិបន្តសហការជាមួយគ្នាទៀត ដើម្បីកំណត់ឈ្មោះក្រសួងដែលមិនទាន់ទូទាត់បុរេប្រទានចំណាយថវិកាចរន្ត ដើម្បីមានវិធានការជំរុញការទូទាត់ជម្រះចំណាយបុរេប្រទានឱ្យបានឆាប់រហ័ស។ ចំពោះផ្នែកចំណាយវិនិយោគ អគ្គនាយកដ្ឋានពាក់ព័ន្ធនឹងតាមដានជំរុញការទូទាត់ចំណាយបុរេប្រទានទៅតាមវឌ្ឍនភាពនៃការអនុវត្តគម្រោងរបស់ស្ថាប័នពាក់ព័ន្ធ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.១៦. ការយកថវិកាចំណាយឆ្នាំ២០១៧មកធ្វើការទូទាត់ប្រតិបត្តិការចំណាយឆ្នាំ២០១៦**

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រង់មាត្រា១១បានចែងថា“ ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់ថ្ងៃទី៣១ ខែធ្នូ” និងសារាចរណែនាំលេខ០០៨សហវ.អថ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ត្រង់ចំណុច**គ.១**បានចែងថា “ ក្នុងរយៈពេលពីថ្ងៃទី១១ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ រដ្ឋទេយ្យករបុរេប្រទានរូតរះប្រមូលឯកសារសក្ខីបត្រ និងលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចបញ្ជូនទៅរតនាគារថ្នាក់កណ្តាលយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ឬរតនាគាររាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ សម្រាប់ថវិកាមិនមែនកម្មវិធី និងត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ សម្រាប់ថវិកាកម្មវិធី”។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុនៃក្រសួងពាណិជ្ជកម្មបានយកប្រតិបត្តិការចំណាយដែលសល់ពីឆ្នាំ២០១៦ មិនទាន់បានធ្វើការទូទាត់មកធ្វើការទូទាត់ឥណទានថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០១៧ មាន ចំនួន ១៤១ ៨២១ ០០០ រៀល នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការណែនាំដល់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុឱ្យធ្វើការទូទាត់ចំណាយថវិកាខាងលើឱ្យបានទាន់ពេលវេលា និងតាមការិយបរិច្ឆេទនៃឆ្នាំថវិកា។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជកម្មសូមទទួលស្គាល់នូវចំណុចខ្វះចន្លោះនេះ ដោយហេតុថា ឥណទានថវិកានៅមានកម្រិត ហើយសកម្មភាពរបស់ក្រសួងមានច្រើនដែលជាហេតុធ្វើឱ្យខ្វះឥណទានថវិកាសម្រាប់ទូទាត់ក្នុងឆ្នាំ ដូច្នេះតម្រូវឱ្យធ្វើការទូទាត់ដោយប្រើប្រាស់ឥណទានឆ្នាំបន្ទាប់។ ប៉ុន្តែទោះជាយ៉ាងណា ក្រសួងពាណិជ្ជកម្មនឹងខិតខំអនុវត្តតាមអនុសាសន៍ដែលផ្តល់ដោយអាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៧. កង្វះខាតក្នុងការត្រួតពិនិត្យឯកសារតម្រូវរបស់ក្រុមហ៊ុនដែលត្រូវដាក់តម្កល់នៅក្រសួងពាណិជ្ជកម្ម

ប្រកាសលេខ១៤២ ព.ណ.ចបព.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីបែបបទ និងនីតិវិធីចុះបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសក្រុមហ៊ុន ត្រង់ប្រការ៥ បានចែងថា " ឯកសារតម្រូវដែលនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

១. កំណត់ហេតុ និងសេចក្តីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន(ច្បាប់ដើម)ចំនួន ៣ច្បាប់
២. ពាក្យស្នើសុំធ្វើការកែប្រែ និងផ្លាស់ប្តូរចំនួន៣ច្បាប់
៣. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មចំនួន៣ច្បាប់(វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណីក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន)
៤. ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្មចំនួន ៣ច្បាប់
៥. ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្មប្រចាំឆ្នាំចំនួន១ច្បាប់
៦. ច្បាប់ចម្លងប៉ាតង់ចំនួន៣ច្បាប់
៧. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ៤x៦របស់ម្ចាស់ក្រុមហ៊ុនថ្មីម្នាក់ៗ (ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី)
៨. ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ(ប្រសិនបើមាន)"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៅមានការខ្វះចន្លោះក្នុងការត្រួតពិនិត្យទៅលើសំណុំឯកសាររបស់ក្រុមហ៊ុនសហគ្រាសអាជីវកម្ម ដែលត្រូវស្នើសុំដាក់តម្កល់ក្នុងការកែប្រែ ឬផ្លាស់ប្តូរលក្ខន្តិកៈឱ្យបានត្រឹមត្រូវ និងពេញលេញនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្មគួរធ្វើការណែនាំដល់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មត្រូវធ្វើការត្រួតពិនិត្យឱ្យបានពេញលេញ និងត្រឹមត្រូវទៅលើសំណុំឯកសារក្នុងការស្នើសុំដាក់តម្កល់កែប្រែ ឬផ្លាស់ប្តូរលក្ខន្តិកៈរបស់ក្រុមហ៊ុនសហគ្រាសអាជីវកម្មឱ្យស្របទៅតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបនឹងករណីនេះ ក្រសួងពាណិជ្ជបានបញ្ជាក់ថា នៅមុនឆ្នាំ២០១៦ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បានបំពេញការងារចុះបញ្ជីដោយដៃ (Paper-Based) ដែលតម្រូវឱ្យក្រុមហ៊ុន ឬសហគ្រាសទាំងអស់បំពេញបែបបទ និងភ្ជាប់ឯកសារយោងជាច្រើន។ យោងតាមប្រកាសលេខ ២១៣ ព.ណចបព.ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបានអនុម័ត និងដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មជាផ្លូវការចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦មក នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មបានអនុវត្តការងារចុះបញ្ជីពាណិជ្ជកម្ម និងការកែប្រែផ្សេងៗតាមការណែនាំរបស់ថ្នាក់ដឹកនាំ ព្រមទាំងអនុលោមតាមខ្លឹមសារប្រកាសខាងលើដើម្បីបង្កភាពងាយស្រួល ក៏ដូចជាបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាជូនសាធារណៈជនទូទៅ នាយកដ្ឋានបានកាត់បន្ថយបែបបទ និងនីតិវិធីផ្សេងៗដែលជាហេតុតម្រូវឱ្យមានទម្រង់លិខិតត្រូវបានកែសម្រួលបន្សុីគ្នាទៅនឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ចំពោះឯកសារតម្រូវក្នុងការដាក់ស្នើ ឬតម្កល់មួយចំនួន

ដែលមិនចាំបាច់ត្រូវបានកាត់បន្ថយក្នុងគោលបំណងជួយសម្រួល និងពន្លឿនការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

ម្យ៉ាងទៀតឯកសារតម្រូវដែលច្បាប់កំណត់ឱ្យក្រុមហ៊ុន សហគ្រាសតម្កល់ទុក គឺត្រូវបានរក្សាទុកក្នុងប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មទាំងអស់ជាផ្លូវការជំនួសការតម្កល់ទុកឯកសារជាក្រដាស់ក្នុងឃ្លាំងឯកសារដែលមិនអាចរក្សាទុកបានយូរអង្វែង និងមិនមានកន្លែងទុកដាក់គ្រប់គ្រាន់។ ក្នុងន័យនេះពាក្យស្នើសុំទាំងអស់ក្នុងឯកសារចុះបញ្ជីថ្មី និងកែប្រែផ្សេងៗត្រូវបានតម្កល់ទុកក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មជាទម្រង់អេឡិចត្រូនិកទាំងអស់ លើកលែងតែឯកសារផ្ទេរភាគហ៊ុនដែលមានស្នាមមេដៃ និងលក្ខន្តិកៈក្រុមហ៊ុនដែលតម្រូវឱ្យក្រុមហ៊ុនយកមកតម្កល់ទុកច្បាប់ដើម។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងតាមដាននូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.១៨. ការពុំមានតារាងទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញនូវសារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយតម្រូវឱ្យស្ថាប័នអនុវត្តកិច្ចលទ្ធកម្មត្រូវចាត់ចែងរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្មសម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា។

តាមការធ្វើសវនកម្មលើឯកសារលទ្ធកម្មទំនិញ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស្ថាប័នអនុវត្តកិច្ចលទ្ធកម្ម) មិនបានរៀបចំតារាងទិន្នន័យតម្លៃទីផ្សារចំពោះទំនិញ (ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារដំណេក សម្ភារការិយាល័យ សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារឹម គ្រឿងឧបភោគបរិភោគ ម៉ូតូ) ដើម្បីធ្វើការប្រៀបធៀបជាមួយអ្នកចូលរួមដេញថ្លៃក្នុងការផ្គត់ផ្គង់ទំនិញទាំងនោះទេ។

ការខកខានពុំមានតារាងទិន្នន័យតម្លៃទីផ្សារនេះ អាចនាំឱ្យតម្លៃនៃការដេញថ្លៃខ្ពស់ជាងតម្លៃទីផ្សារ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួររៀបចំតារាងទិន្នន័យតម្លៃទីផ្សារចំពោះទំនិញដែលត្រូវទិញ ដើម្បីប្រៀបធៀបជាមួយតម្លៃដែលអ្នកដេញថ្លៃផ្តល់ឱ្យក្រសួង និងដើម្បីធានាបាននូវការសន្សំសំចៃថវិការដ្ឋ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និងបានបំភ្លឺថា ក្នុងអំឡុងពេលពិនិត្យវាយតម្លៃលើឯកសារដេញថ្លៃ ក្រសួងបានយកតារាងតម្លៃប្រចាំខែ ដែលចេញដោយអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមកប្រៀបធៀប។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀ។

### ៣.១.១៩. ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ និងសេវា ដែលមានសកម្មភាពអាជីវកម្មមិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា(ប៉ាតង់)

លិខិតជូនដំណឹងលេខ៦១៣៥ សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ បានណែនាំបញ្ជាក់ចំពោះអ្នកដេញថ្លៃត្រូវបំពេញបន្ថែមនូវប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃត្រូវមានរបរឱ្យស្របគ្នានឹងមុខរបរដែលត្រូវចូលរួមដេញថ្លៃ។

តាមការពិនិត្យឯកសារដែលក្រុមហ៊ុនដាក់ពាក្យចូលរួមដេញថ្លៃនៅក្នុងកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០១៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន០២ ដោយធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាលើការផ្គត់ផ្គង់សម្ភារដំណេក សម្ភារបរិភោគ សម្ភារអនាម័យ ជូនចំពោះជនក្រីក្រ ជនពិការ ដែលសកម្មភាពអាជីវកម្ម (ប៉ាតង់) ទាំងនោះមានសកម្មភាពអាជីវកម្មមិនស្របទៅនឹងកម្មវត្ថុនៃកិច្ចសន្យានោះឡើយ។ កត្តានេះអាចនាំឱ្យការអនុវត្តកិច្ចលទ្ធកម្មមិនមានតម្លាភាព និងគណនេយ្យភាព។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរតម្រូវឱ្យអ្នកចូលរួមដេញថ្លៃបំពេញតាមលក្ខខណ្ឌក្នុងលិខិតជូនដំណឹងស្តីពីការចូលរួមដេញថ្លៃផ្គត់ផ្គង់ទំនិញ និងសេវា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលយកអនុសាសន៍ដើម្បីអនុវត្ត។ ទន្ទឹមនឹងនោះ ក្រសួងបានបំភ្លឺថា នៅចុងការិយបរិច្ឆេទឆ្នាំ២០១៧ បន្ទាប់ពីដេញថ្លៃ រួចគណៈកម្មាធិការលទ្ធកម្មបានពិនិត្យអង្កេត និងវាយតម្លៃយ៉ាងយកចិត្តទុកដាក់ ក្រោយមកក៏សម្រេចជ្រើសរើសក្រុមហ៊ុនណាដែលមានតម្លៃសមរម្យជាងគេ តែក្រុមហ៊ុនបានដាក់ប៉ាតង់ (កាលៈទេសៈចុងការិយបរិច្ឆេទ) មិនស្របតាមកម្មវត្ថុនៃសេចក្តីជូនដំណឹងមែន។

ផ្អែកតាមការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

**៣.១.២០. ភាពយឺតយ៉ាវក្នុងការអនុវត្តគោលនយោបាយប្រគល់ដីធ្លីរបស់រាជរដ្ឋាភិបាលជូនអតីតមន្ត្រីសង្គមកិច្ចដែលបានស្នាក់នៅ និងកំពុងកាន់កាប់**

ការពន្លឿនការអនុវត្តនីតិវិធីក្នុងការជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋនូវអចលនវត្ថុ រួមមានដី និងកន្លែងស្នាក់នៅ ដើម្បីប្រគល់ជូនប្រជាពលរដ្ឋ ឬមន្ត្រីរាជការទទួលបានកម្មសិទ្ធិស្របច្បាប់ ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញលិខិតជូនដំណឹងលេខ៧១៧២ សហវ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ក្នុងស្មារតីទទួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់ចំពោះការលើកកម្ពស់ជីវភាព សុខុមាលភាព និងសុខដុមរមនាជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានណែនាំឱ្យជំរុញអនុវត្តគោលនយោបាយប្រគល់ដី និងទីតាំងរបស់រដ្ឋមួយចំនួនជូនប្រជាពលរដ្ឋ ឬមន្ត្រីរាជការដែលបាននិងកំពុងរស់នៅអស់រយៈពេលជាយូរលង់មកហើយលើទីតាំងនេះ ដើម្បីទទួលបានកម្មសិទ្ធិស្របច្បាប់។ ជាក់ស្តែង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំងនៅមិនទាន់បានអនុវត្តតាមលិខិតជូនដំណឹងខាងលើនេះទេ ដោយអតីតមន្ត្រីសង្គមកិច្ចកំពុងស្នាក់នៅ និងកាន់កាប់ដីទំហំ២២៥ ម៉ែត្រការេ ក្នុងមន្ទីរសង្គមកិច្ច។

ពាក់ព័ន្ធនឹងករណីនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរជំរុញ និងណែនាំមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំង ពន្លឿនការដោះស្រាយករណីខាងលើឱ្យបានលឿន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបំភ្លឺថា ក្រសួងនឹងពិនិត្យ និងរៀបចំក្រុមការងារចុះពិនិត្យករណីអតីតមន្ត្រីសង្គមកិច្ចរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំង និងធ្វើរបាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិនៅពេលក្រោយ។

តាមរយៈការបំភ្លឺរបស់ក្រសួង អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២១. នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារនៅខ្វះចន្លោះ

ការបង្កើតឱ្យមានយន្តការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ។ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ដើម្បីជួយប្រធានស្ថាប័នគ្រប់គ្រងអង្គភាពក្រោមឱវាទ អនុវត្តការងារជំនាញបានល្អ ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

តាមរយៈការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនបានអនុវត្តការងារសវនកម្មឱ្យបានពេញលេញនោះទេដោយបានអនុវត្តការងារសវនកម្មបានតែមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាតែប៉ុណ្ណោះ។ លើសពីនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏មិនបានផ្ញើរបាយការណ៍នៃការចុះធ្វើសវនកម្មទាំងនោះមកអាជ្ញាធរសវនកម្មជាតិនោះទេ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរជំរុញនាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារជំនាញឱ្យបានពេញលេញ និងផ្ញើរបាយការណ៍សវនកម្មមកអាជ្ញាធរសវនកម្មជាតិ។

ចំពោះករណីខាងលើនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលយកអនុសាសន៍ និងណែនាំដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុងឱ្យអនុវត្តការងារជំនាញឱ្យពេញលេញព្រមទាំងផ្ញើរបាយការណ៍សវនកម្មជូនអាជ្ញាធរសវនកម្មជាតិផង។

### ៣.១.២២. ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង

ព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់ជំពូកទី៥ ការត្រួតពិនិត្យ និងសវនកម្ម ត្រង់មាត្រា៤៦ បានចែងថា "គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល"។ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងសង្កេតឃើញថា សម្រាប់ការិយបរិច្ឆេទ២០១៧ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៅពុំទាន់បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យតាមដាន និងបង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការការងារនៅក្នុងអង្គភាពនៅឡើយ។

អាស្រ័យហេតុនេះ ដើម្បីឱ្យមានប្រសិទ្ធភាពនៃការអនុវត្តការងារ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាគួរបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងឱ្យស្របតាមព្រះរាជក្រឹត្យខាងលើ។

ឆ្លើយតបនឹងការលើកឡើង វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ហើយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នឹងបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង។

តាមរយៈការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

### ៣.១.២៣. ការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកំណត់

ប្រការ៤ នៃកិច្ចសន្យាស្តីពីការរៀបចំជួសជុលកែលម្អទីតាំងធ្វើការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧ បានចែងថា "អ្នកទទួលការ" ត្រូវកក់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាដែលមានទឹកប្រាក់ស្មើនឹងដប់ (១០) ភាគរយ នៃតម្លៃកិច្ចសន្យាសរុបជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា។ ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញយ៉ាងយូរ

ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់។ ប្រការ៩ នៃកិច្ចសន្យានេះក៏បានចែងផងដែរថា "អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល១២ខែ (ដប់ពីរខែ) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់"ការងារ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការរៀបចំជួសជុលកែលម្អទីតាំងធ្វើការងាររបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបានចាប់ផ្តើមអនុវត្តនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ និងត្រូវបានបញ្ចប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ព្រមទាំងបានចេញវិញ្ញាបនប័ត្របញ្ជាក់ការបញ្ចប់ការងារជួសជុលកែលម្អនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ ប៉ុន្តែការដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា បានអនុវត្តមុនកាលបរិច្ឆេទកំណត់តាមរយៈលិខិតលេខ១១៦៣លទ_១៧អអក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។

ឆ្លើយតបនឹងការលើកឡើងនេះ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិក្នុងការរក្សាទុកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ឱ្យបានសមស្របតាមប្រការនៃកិច្ចសន្យា។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.២៤. ការពុំបានចែងពីការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យានៅក្នុងកិច្ចសន្យា**

ចំណុច៦ នៃលក្ខខណ្ឌទូទៅនៃកិច្ចសន្យាបានចែងថា "អ្នកផ្គត់ផ្គង់" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់ (១០) ភាគរយនៃតម្លៃកិច្ចសន្យាសរុបនៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិរាជធានី ខេត្ត ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា កិច្ចសន្យាស្តីពីការបង់ថ្លៃសេវាថែទាំ និងជួសជុលប្រព័ន្ធគ្រប់គ្រងអាជីវកម្មអគ្គិសនី សម្រាប់ឆ្នាំ២០១៧ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ រវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុន អ៊ី ផៅវ័រ ពុំបានចែងអំពីការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។

ឆ្លើយតបនឹងការលើកឡើងនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ថា កិច្ចសន្យាលើសេវាថែទាំ និងជួសជុលប្រព័ន្ធគ្រប់គ្រងអាជីវកម្មអគ្គិសនី រវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុន អ៊ី ផៅវ័រ គឺបានអនុវត្តតាមគោលការណ៍ដោយឡែកផ្អែកលើវិធីសាស្ត្រនៃការចុះកិច្ចសន្យាផ្ទាល់ដោយសារ ៖

ការដេញថ្លៃលើកទី១ ចាប់ពីឆ្នាំ២០១៤ ពុំមានក្រុមហ៊ុនផ្សេងណាចូលមកទទួលបន្ទុកលើសេវាថែទាំនេះឡើយ ដោយសារកម្មវិធីនេះជាកម្មវិធីដែលបង្កើតដោយក្រុមហ៊ុន អ៊ី ផៅវ័រ ដែលត្រូវបានអាជ្ញាធរអគ្គិសនីកម្ពុជាទិញផ្តាច់មុខ។

កញ្ចប់ថវិកាលើការថែទាំនេះ ជាកញ្ចប់ថវិកាម៉ៅការប្រចាំឆ្នាំ សម្រាប់ការថែទាំកម្មវិធីដែលសេវាករអគ្គិសនីបាននិងកំពុងប្រើប្រាស់ទូទាំងប្រទេស និងជាកញ្ចប់ថវិកាដែលមានការអនុម័តយល់ព្រមពីរាជរដ្ឋាភិបាលរួចហើយ។

ដោយនៅក្នុងកិច្ចសន្យាក្រុមហ៊ុន អ៊ី ផៅវ័រ ជាអ្នកទទួលបន្ទុករ៉ាប់រងទាំងស្រុងលើការថែទាំកម្មវិធីនេះ ឱ្យដំណើរការដោយរលូន ទោះបីជាសេវាករអគ្គិសនីនៅឆ្ងាយៗក៏ដោយ។ នេះជាផលប្រយោជន៍ និងភាពងាយស្រួលក្នុងការតាមដានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើអាជីវកម្មប្រចាំឆ្នាំរបស់សេវាករនីមួយៗ។ ការចេញចំណាយមុន ក្នុងការថែទាំកម្មវិធីដែលសេវាករអគ្គិសនីគ្រប់តំបន់

កំពុងប្រើនេះ ជាបន្ទុករបស់ក្រុមហ៊ុន អ៊ី ផៅវ័រ ហើយអាជ្ញាធរអគ្គិសនីកម្ពុជា នឹងបង់តាមក្រោយទៅក្រុមហ៊ុនវិញ បន្ទាប់ពីពិនិត្យឃើញថា សេវាថែទាំមានដំណើរការល្អតាមលក្ខខណ្ឌនៃកិច្ចសន្យា។

ហេតុនេះហើយដែលជាកត្តាក្នុងការចរចាចុះកិច្ចសន្យា អាជ្ញាធរអគ្គិសនីកម្ពុជាយើងពុំបានតម្រូវឱ្យក្រុមហ៊ុន អ៊ី ផៅវ័រ តំកល់ប្រាក់កក់កិច្ចសន្យាមកឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.២៥. ការពុំបានអនុវត្តគម្រោងលទ្ធកម្ម**

ផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរអគ្គិសនីកម្ពុជា ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ បានលើកឡើងនូវគម្រោងទិញគ្រឿងសង្ហារឹមការិយាល័យដែលស្ថិតនៅក្នុងគម្រោងលទ្ធកម្មទំនិញដោយវិធីសាស្ត្រប្រកួតប្រជែងក្នុងស្រុក។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការទិញគ្រឿងសង្ហារឹមការិយាល័យជាក់ស្តែងពុំបានអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈ ហើយក៏ពុំបានបង្ហាញក្នុងរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរអគ្គិសនីកម្ពុជាដែរ។

ឆ្លើយតបនឹងការលើកឡើងនេះ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិក្នុងការអនុវត្តគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាពខ្ពស់។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តតាមដានលើការកែលម្អអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

**៣.១.២៦. ការចំណាយពុំបានអនុវត្តតាមវិធីសាស្ត្រលទ្ធកម្ម**

តាមសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ ត្រង់ចំណុច III បានចែងថា «ក្រសួង ស្ថាប័ន ត្រូវប្រមូលផ្តុំតម្រូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នា ស្រដៀងគ្នា ត្រូវបញ្ចូលគ្នាជាក្រុមធំមួយហៅថាកញ្ចប់លទ្ធកម្មសម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើក»។ ឧបសម្ព័ន្ធនៃសារាចរណែនាំខាងលើ ក៏បានកំណត់ទឹកប្រាក់សម្រាប់ការអនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃលើប្រភេទលទ្ធកម្មទំនិញ សំណង់ ត្រូវមានទឹកប្រាក់ចាប់ពី ២០ លានរៀលដល់ក្រោម ១០០ លានរៀល និងប្រភេទលទ្ធកម្មសេវាមានទឹកប្រាក់ក្រោម ១០០ លានរៀល។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងការិយបរិច្ឆេទ២០១៧ គ្រឹះស្ថានអង្គរមានផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែចំពោះការអនុវត្តចំណាយថវិកាជាក់ស្តែង គ្រឹះស្ថានអង្គរបានធ្វើការចុះកិច្ចសន្យាផ្ទាល់ និងទិញផ្ទាល់នូវមុខទំនិញមួយចំនួន ដូចជាការទូទាត់ថ្លៃក្រាលការូឡា និងជួសជុលដំបូល (សំណង់អគាររដ្ឋបាល) និងចំណាយទិញសម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ ដែលមានទឹកប្រាក់ចាប់ពី ជាង ១១ លានរៀលដល់ជាង៥៧លានរៀល ដោយពុំបានអនុវត្តឱ្យបានត្រឹមត្រូវតាមវិធីសាស្ត្រលទ្ធកម្មជាធរមាន។ គ្រឹះស្ថានអង្គរ គួរអនុវត្តតាមសារាចរណែនាំខាងលើឱ្យមានប្រសិទ្ធភាព។

គ្រឹះស្ថានអង្គរបានធ្វើការបំភ្លឺថា (ក)-ការរៀបចំក្រាលការូឡា និងជួសជុលដំបូល ដោយការងារនេះជាការងារចាំបាច់និងបន្ទាន់ ដើម្បីផ្តល់សេវាជូនភ្ញៀវទេសចរណ៍អន្តរជាតិនៅក្នុងរដូវវស្សាព្រោះទីកន្លែងដែលរៀបចំ និងជួសជុលនេះគឺមានទឹកភ្លៀងដក់ជោកជាំ និងស្រក់ទឹកភ្លៀងលើភ្ញៀវ

ទេសចរអន្តរជាតិដែលកំពុងឈរវង់ចាំទិញប័ណ្ណចូលទស្សនាអង្គរ។ ចំពោះការងារនេះ គ្រឹះស្ថានបានធ្វើការចរចាថ្លៃជាមួយជាងម៉ៅការដែលមាននៅក្នុងខេត្តសៀមរាបនេះចំនួន០២នាក់ ផងដែរ ព្រោះជាងមិនសូវហ៊ានមកធ្វើការជួសជុល និងក្រាលការូឡានៅទីនេះទេ ដោយតំបន់នេះជាតំបន់ហាមឃាត់ធ្វើការសាងសង់ដោយអាជ្ញាធរអប្សរា។ (ខ)-ចំពោះការទិញសម្ភារផ្គត់ផ្គង់សម្អាតនិងអនាម័យ ដោយការងារនេះជាការងារចាំបាច់ និងបន្ទាន់ ដើម្បីផ្តល់សេវាជូនភ្ញៀវទេសចរលើបញ្ហាបង្គន់អនាម័យតាមបណ្តាប្រាសាទក្នុងរមណីយដ្ឋានអង្គរនៅពេលដែលមានការខ្វះសម្ភារទាំងអស់នេះ សម្រាប់ប្រើប្រាស់នៅក្នុងចន្លោះពេលដែលការដេញថ្លៃកំពុងតែអនុវត្តមិនទាន់បានធ្វើការផ្គត់ផ្គង់ទាន់ពេលវេលា។ ជាពិសេស សម្ភារមួយចំនួននេះ គ្រឹះស្ថានយល់ឃើញថា ជាសម្ភារច្រើនប្រភេទនិងតូចតាច ដូចជា សាប៊ូគិតជាកាន អំបោស បោយទឹក អំពូលអ៊ុយ គន្លឹះទ្វារបង្គន់ ប្រអប់ក្រដាសអនាម័យ ជាលសម្រាម ថង់ដាក់សម្រាម ដែលជាតម្រូវការប្រចាំថ្ងៃ និងពុំមានកន្លែងយកមកស្តុកទុកសម្រាប់រយៈពេល៦ខែនូវរបស់ទាំងនេះបានទេ។ គ្រឹះស្ថាននឹងខិតខំអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

អាជ្ញាធរសវនកម្មជាតិ បានឃើញការឆ្លើយបំភ្លឺរបស់គ្រឹះស្ថានអង្គរ។ អាជ្ញាធរសវនកម្មជាតិ នឹងបន្តតាមដានលើការកែលម្អលើការអនុវត្តតាមអនុសាសន៍សវនកម្មជាបន្តទៀត។

## ៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.២.១. ការប្រមូលពន្ធប៉ាតង់

ពន្ធប៉ាតង់ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំ ដែលអ្នកជាប់ពន្ធត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាងដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន៣ ០០០ ០០០រៀលនៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។ តាមការធ្វើតេស្តលើសាខាក្រុមហ៊ុននៅតាមបណ្តាសាខាពន្ធដារខេត្តមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានសាខាក្រុមហ៊ុនចំនួន៤២៤ដែលធ្វើអាជីវកម្មនៅតាមខេត្តផ្សេងគ្នា ក្នុងនោះ សាខាក្រុមហ៊ុនមួយចំនួនធំបានបង់ពន្ធប៉ាតង់រួច ប៉ុន្តែសាខាក្រុមហ៊ុនមួយចំនួនទៀតមិនទាន់បានបង់ពន្ធប៉ាតង់ទេ។

ការខកខានក្នុងការបង់ពន្ធប៉ាតង់របស់ក្រុមហ៊ុនទាំងនោះ នាំឱ្យការប្រមូលពន្ធប៉ាតង់មិនអស់លទ្ធភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានវិធានការបន្ថែមទៀត ដើម្បីប្រមូលពន្ធប៉ាតង់ឱ្យអស់លទ្ធភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺបន្ថែមថា នៅមានសាខាក្រុមហ៊ុនមួយចំនួនប៉ុណ្ណោះដែលមិនទាន់បានបង់ពន្ធប៉ាតង់ ព្រោះក្រុមហ៊ុនមួយចំនួនត្រូវផ្ទេរកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធមធ្យមទៅជាអ្នកជាប់ពន្ធធំ ខ្លះក៏បានបង់នៅកន្លែងដែលស្នាក់ការកណ្តាលរបស់គាត់បានចុះបញ្ជី និងមួយចំនួនទៀតជាសហគ្រាសលទ្ធកម្ម។ ក្រុមហ៊ុនខ្លះធ្វើបច្ចុប្បន្នភាពមិនទាន់ចប់ និងម្ចាស់ក្រុមហ៊ុនខ្លះមិនព្រមសហការក្នុងការផ្តល់ឯកសារពាក់ព័ន្ធនានា ដែលជាហេតុធ្វើឱ្យការប្រមូលពន្ធប៉ាតង់ពុំបានអស់។ តាមរយៈការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងការអប់រំផ្សព្វផ្សាយអំពីកាតព្វកិច្ចសារពើពន្ធ ឃើញថា មានសហគ្រាសជាច្រើនបានបង់ពន្ធប៉ាតង់សាខារបស់ខ្លួន ហើយក៏នៅមានសហគ្រាសមួយចំនួនទៀត កំពុងបន្តបំពេញកាតព្វកិច្ចបង់ពន្ធប៉ាតង់របស់ខ្លួនដែរ។

តាមរយៈការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

### ៣.២.២. ការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ

ប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ត្រង់ប្រការ២៣ បានចែងថា "របាយការណ៍សមិទ្ធកម្មគឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផល និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្ត ចង្កោមសកម្មភាព អនុកម្មវិធី ឬកម្មវិធីរបស់អង្គភាពថវិកា ក្នុងការរួមចំណែកសម្រេចគោលបំណង គោលនយោបាយរបស់ក្រសួង ស្ថាប័ន។ អង្គភាពថវិកានៃក្រសួង ស្ថាប័ន ត្រូវតាមដានការអនុវត្ត ថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និង សូចនាករលទ្ធផលចុងក្រោយ ដោយអនុលោមទៅតាមទម្រង់តារាងគំរូម និងតាមទម្រង់នៃប្រភេទ របាយការណ៍របស់ក្រសួង ស្ថាប័នសាមី។ របាយការណ៍សមិទ្ធកម្មទាំងអស់ ត្រូវធ្វើឡើងតាមកាល បរិច្ឆេទដូចខាងក្រោម ៖

– របាយការណ៍សមិទ្ធកម្មប្រចាំឆមាស កម្រិតចង្កោមសកម្មភាព និង/ឬកម្រិតអនុកម្មវិធី ត្រូវផ្ញើមកយ៉ាងយូរបំផុត២០ថ្ងៃ បន្ទាប់ពីការបញ្ចប់ការអនុវត្តនៃឆមាសទី១។

– របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំដល់កម្រិតកម្មវិធីត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមខែមីនា នៃឆ្នាំបន្ទាប់។

តាមរយៈការចុះសវនកម្មចាប់ខែមីនា ឆ្នាំ២០១៧ អង្គភាពថវិកានៃមន្ទីរជំនាញមួយចំនួន ក្នុងខេត្តចំនួន៥ ពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំឡើយ ក្នុងនោះរួមមាន៖

១. ខេត្តតាកែវមានចំនួន១០មន្ទីរ គឺមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរ ទេសចរណ៍ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរឧស្សាហកម្ម និង សិប្បកម្ម មន្ទីរធម្មការ និងសាសនា មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរព័ត៌មាន មន្ទីរកិច្ចការនារី។

២.ខេត្តស្វាយរៀងមានចំនួន៩មន្ទីរ គឺមន្ទីរធនធានទឹក និងឧតុនិយម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរឧស្សាហកម្ម និង សិប្បកម្ម មន្ទីររ៉ែ និងថាមពល មន្ទីរបរិស្ថាន មន្ទីរអភិវឌ្ឍន៍ជនបទ។

៣.ខេត្តពោធិ៍សាត់មានចំនួន៧មន្ទីរ គឺមន្ទីរកិច្ចការនារី មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរព័ត៌មាន មន្ទីរទេសចរណ៍ មន្ទីរសាធារណការ និង ដឹកជញ្ជូន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ។

៤.ខេត្តកំពង់ស្ពឺមានចំនួន៦មន្ទីរ គឺមន្ទីរធនធានទឹក និងឧតុនិយម មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរទេសចរណ៍ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥.ខេត្តបាត់ដំបងមានចំនួន៦មន្ទីរ គឺមន្ទីរពាណិជ្ជកម្ម មន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរឧស្សាហកម្ម និងសិប្បកម្ម មន្ទីរប្រៃសណីយ៍។

ដោយសារការពុំបានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំ នាំឱ្យពុំមាន សក្ខីកម្មក្នុងការវាស់វែងនូវប្រសិទ្ធភាព ប្រសិទ្ធផល នៃការអនុវត្តថវិកាតាមកម្មវិធីរបស់អង្គភាព។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្តគួរណែនាំមន្ទីរខាងលើអនុវត្តឱ្យបានសមស្របតាម ប្រកាសណែនាំខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តបានឯកភាព និងជំរុញការអនុវត្តការងារនេះ ឱ្យបាននាពេលខាងមុខ។

តាមរយៈការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

**៣.២.៣. ការយឺតយ៉ាវក្នុងការប្រគល់ទទួលសំណង់វិនិយោគសម្រាប់អាជីវកម្មភាស៊ី**

កិច្ចសន្យា និងសៀវភៅបន្ទុកស្តីពីការធ្វើវិនិយោគបានកំណត់ថា ភាគី "ខ" ត្រូវធានាទាំងស្រុងអំពីគុណភាព សុវត្ថិភាពនៃការសាងសង់សំណង់ ដោយអនុវត្តតាមបទដ្ឋានបច្ចេកទេស និងមានការតាមដានត្រួតពិនិត្យពីគណៈកម្មការចម្រុះរបស់ខេត្ត បន្ទាប់ពីសាងសង់ចប់សព្វគ្រប់ ត្រូវមានកំណត់ហេតុវាយតម្លៃពីគណៈកម្មការចម្រុះ ដែលមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យលើគុណភាព និងបរិមាណ ដោយផ្ទៀងផ្ទាត់តាមគម្រោងកំណត់។

តាមរយៈការធ្វើសវនកម្មនៅខេត្តចំនួន០៣គឺ ខេត្តសៀមរាប ស្វាយរៀង និងរតនគិរី សម្រាប់ការិយបរិច្ឆេទ២០១៧ ការវាយតម្លៃលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកសម្រាប់ការងារសាងសង់សំណង់វិនិយោគ ដើម្បីទទួលបានការធ្វើអាជីវកម្មភាស៊ីពីគណៈកម្មការចម្រុះ ដើម្បីធ្វើការប្រគល់ទទួល មានការយឺតយ៉ាវ ជាក់ស្តែងមាននៅ៖

១-ខេត្តសៀមរាប៖ ផ្សារលើធំថ្មី ផ្សារក្រោមក្រុងសៀមរាប ផ្សារពួកស្រុកពួក ផ្សារក្រឡាញ់ស្រុកក្រឡាញ់ ផ្សាររលួស ផ្សារអង្រ្គងស្រុកប្រាសាទបាគង និងផ្សារកំពង់ក្តីស្រុកជីក្រែង។

២-ខេត្តស្វាយរៀង៖ ចំណតរថយន្តផ្សារវាលយន្ត ក្រុងស្វាយរៀង ផ្សារជីភូ ក្រុងបាវិត ផ្សារថ្មីប្រសូតិ ស្រុកស្វាយទាប។

៣-ខេត្តរតនគិរី៖ ផ្សារបានលុង។

ដោយសារការយឺតយ៉ាវក្នុងការប្រគល់ទទួលសំណង់វិនិយោគទាំងនេះ នាំឱ្យសំណង់វិនិយោគអាចអនុវត្តពុំបានត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា និងសៀវភៅបន្ទុក។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត គួរជំរុញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមត្ថកិច្ចពាក់ព័ន្ធ ចុះពិនិត្យវាយតម្លៃលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមានសមភាពគ្នាសម្រាប់អ្នកវិនិយោគដទៃផ្សេងទៀត ។

ឆ្លើយតបនឹងការលើកឡើងនេះ រដ្ឋបាលខេត្តខ្លះមិនបានឆ្លើយបំភ្លឺទេ ខ្លះទៀតបានទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិមកកែលម្អ និងជំរុញអង្គភាពឱ្យខិតខំអនុវត្តតាមនីតិវិធីច្បាប់ឱ្យបានត្រឹមត្រូវ។

តាមរយៈការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

## ៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៧ នាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួនដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឲ្យកត់សម្គាល់ និងកោតសរសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

**៤.១. ការប្រមូលព័ត៌មានសហគ្រាសមួយចំនួនដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័ន:** ដើម្បីគ្រប់គ្រងការប្រមូលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតបទដ្ឋាន និងនីតិវិធីទាក់ទងទៅនឹងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ ការប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមបណ្ដាក្រសួង ស្ថាប័ននានា ជូនទៅនាយកដ្ឋាននានា និងសាខាពន្ធដារខេត្ត ខណ្ឌ។ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតក្រុមការងារមួយចំនួន និងបានសហការធ្វើការងារជាមួយក្រសួងពាណិជ្ជកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាគារកម្ពុជា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ប៉ុន្តែអគ្គនាយកដ្ឋានពន្ធដារមិនទាន់បានប្រមូលព័ត៌មានសហគ្រាសដែលបានចុះបញ្ជីតាមក្រសួង ស្ថាប័នមួយចំនួនទៀត។ ការខកខានក្នុងការប្រមូលព័ត៌មានអំពីសហគ្រាសដែលបានចុះបញ្ជីនៅតាមក្រសួង ស្ថាប័ន នាំឱ្យនាយកដ្ឋាននានា និងសាខាពន្ធដារខេត្ត ខណ្ឌ ដែលជាអង្គភាពអនុវត្តការប្រមូលពន្ធមិនមានព័ត៌មានអំពីអ្នកជាប់ពន្ធដែលខ្លួនគ្រប់គ្រង ដើម្បីពិនិត្យបញ្ជាក់លើការប្រកាសបង់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺថា អគ្គនាយកដ្ឋានពន្ធដារបានធ្វើការសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងបានបង្កើតក្រុមការងារមួយចំនួនរួចមកហើយ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្ទៀងផ្ទាត់ ក៏ដូចជាប្រមូលព័ត៌មានរបស់អ្នកជាប់ពន្ធដើម្បីពិនិត្យបញ្ជាក់លើការបំពេញកាតព្វកិច្ចពន្ធដាររបស់អ្នកជាប់ពន្ធ។

**៤.២. ការគ្រប់គ្រងអ្នកជាប់ពន្ធ:** រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់បេសកកម្មជូនអគ្គនាយកដ្ឋានពន្ធដារនូវភារកិច្ច ដូចជា៖ ផ្ដល់សេវាដល់អ្នកជាប់ពន្ធ ប្រមូលចំណូលពន្ធ និងអនុវត្តកម្មវិធីចាប់បង្ខំចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ។ ផ្អែកតាមស្ថិតិសហគ្រាសប្រចាំខែ ឆ្នាំ របស់ការិយាល័យស្ថិតិសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សហគ្រាសមួយចំនួនតូចពុំបានដាក់លិខិតប្រកាសពន្ធទេ។ ការខកខានរបស់អ្នកជាប់ពន្ធក្នុងការដាក់លិខិតប្រកាសពន្ធទៅតាមទម្រង់ និងទីកន្លែងកំណត់ បានផ្ដល់ផលលំបាកចំពោះរដ្ឋបាលសារពើពន្ធក្នុងការប្រមូលពន្ធ និងជាបច្ច័យមួយនៃការគេចវេសពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺថា សហគ្រាសដែលមិនបានមកដាក់លិខិតប្រកាស គឺរួមមានទាំងសហគ្រាសដែលបាត់ខ្លួនផងដែរ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារបានបង្កើតនូវប្រព័ន្ធ Auto Printout ដើម្បីព្រីនលិខិតជូនដំណឹងសម្រាប់អ្នកជាប់ពន្ធ ដែលខកខានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធទាន់ពេលវេលា និងដើម្បីធ្វើការចែកជូនទៅដល់ក្រុមហ៊ុន សហគ្រាសទាំងនោះឱ្យមកបំពេញកាតព្វកិច្ចសារពើពន្ធ។ ក្រោយពីចេញលិខិតរំលឹករួចហើយ បើក្រុមហ៊ុនសហគ្រាសទាំងនោះ នៅតែមិនចូលខ្លួនមកបំពេញកាតព្វកិច្ចសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់វិធានការ ដោយធ្វើការដកហូតវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ជាដើម។ល។

**៤.៣. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ:** ច្បាប់ស្ដីពីសារពើពន្ធបានកំណត់ឱ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្ដល់ព័ត៌មានចាំបាច់ជូនរដ្ឋបាល

សារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការធ្វើសវនកម្មលើសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន១៤០ក្រុមហ៊ុនសហគ្រាស ក្នុងការិយបរិច្ឆេទ២០១៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអ្នកជាប់ពន្ធចំនួន៩៦ក្រុមហ៊ុនសហគ្រាស (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន៣៤ និងស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមចំនួន៦២) មិនបានកាន់កាប់កត់ត្រា និងថែរក្សាទុកបញ្ជីកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់នោះទេ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺថា ករណីនេះ កន្លងមកនាយកដ្ឋានសវនកម្មសហគ្រាស ក៏ដូចជាអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារតែងតែបានជួយពន្យល់ណែនាំដល់សហគ្រាសទាំងឡាយ ពិសេសនៅពេលចុះធ្វើសវនកម្ម ធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធធ្វើការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ លើសពីនេះទៀត អគ្គនាយកដ្ឋានពន្ធដារតែងតែធ្វើការអប់រំ ផ្សព្វផ្សាយ និងណែនាំដល់អ្នកជាប់ពន្ធទាំងអស់តាមរយៈការធ្វើសិក្ខាសាលា ដើម្បីជំរុញការអប់រំអ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ពន្ធដារ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ។

**៤.៤. ការបំពេញកាតព្វកិច្ចសារពើពន្ធ:** ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធបានកំណត់ឱ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។ តាមការធ្វើសវនកម្មលើបញ្ជីឈ្មោះក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជី និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះ លោក លោកស្រី នាយកក្រុមហ៊ុន សហគ្រាសនីមួយៗឱ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំនៅអង្គភាពពន្ធដារ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៧ មានក្រុមហ៊ុនមួយចំនួនមិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១៧នោះទេ។ ករណីក្រុមហ៊ុនមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារបានខិតខំជំរុញណែនាំដល់នាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត-ខណ្ឌ បន្តការធ្វើសវនកម្មឱ្យបានម៉ឺងម៉ាត់ និងដាក់ទណ្ឌកម្មពិន័យតាមច្បាប់ចំពោះក្រុមហ៊ុនសហគ្រាសដែលខកខានមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធ។ ចំពោះការមិនបានដាក់ទោសទណ្ឌតាមមាត្រា១២៩ បទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារនៅតែព្យាយាមប្រើប្រាស់វិធានការទន់ភ្លន់ និងបន្តអប់រំដល់អ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់ស្តីពីសារពើពន្ធសិន។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានប្រើប្រាស់វិធានការរដ្ឋបាលជាច្រើន ដូចជា ការឃាត់ទុកការផ្ទេរកម្មសិទ្ធិ មិនឱ្យបើកក្រុមហ៊ុនថ្មី និងមិនឱ្យលក់ភាគហ៊ុនជាដើម។ល។

**៤.៥. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ:** សហគ្រាសវិនិយោគទាំងឡាយដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំរបស់សហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ។ ក្នុងឆ្នាំ២០១៧ តាមការធ្វើតេស្តលើសំណុំឯកសារមួយចំនួននៅ

នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារដែលបានចុះធ្វើសវនកម្មលើសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យ ត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យចំនួន១២៧ ក្នុងនោះមានសហគ្រាសចំនួន៧ មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ រីឯក្រុមហ៊ុនសហគ្រាសផ្សេងទៀតនៅពុំឃើញមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យឡើយ។ ករណីនេះ ក្រុមប្រឹក្សាជាតិគណនេយ្យកំពុងផ្សព្វផ្សាយការងារនេះដល់ភាគីពាក់ព័ន្ធ ហើយកន្លងមកអគ្គនាយកដ្ឋានពន្ធដារខិតខំជំរុញយ៉ាងសកម្មតាមរយៈការចុះធ្វើសវនកម្ម និងពន្យល់ពីសារៈសំខាន់ចំពោះសហគ្រាសដែលត្រូវភ្ជាប់មកជាមួយរបាយការណ៍សវនកម្មពីសវនករដែលមានវិជ្ជាជីវៈ។ លើសពីនេះក៏មានការលើកទឹកចិត្តចំពោះក្រុមហ៊ុនសហគ្រាសដែលមានរបាយការណ៍សវនកម្មពីសវនករឯករាជ្យផងដែរ។

**៤.៦. ការប្រើប្រាស់វិក្កយបត្រៈ** តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឲ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែមគឺត្រូវមានចុះលេខរៀងត្រឹមត្រូវឲ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ តាមរយៈការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាជីវកម្មរបបស្វ័យប្រកាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់ត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជា វិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ..។ ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានច្បាស់លាស់អាចពុំបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ និងការធ្វើសវនកម្ម។ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺថា អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងចាត់វិធានការជាបន្តបន្ទាប់ ដោយបានធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ រៀបចំសិក្ខាសាលាណែនាំដល់អ្នកជាប់ពន្ធ ផ្ញើលិខិតជូនដំណឹងពាក់ព័ន្ធនឹងការប្រើប្រាស់វិក្កយបត្រជូនដល់សហគ្រាស និងណែនាំដល់មន្រ្តីពន្ធដារពាក់ព័ន្ធគ្រប់ផ្នែកពិនិត្យមើលឱ្យបានម៉ឺងម៉ាត់ និងចាត់វិធានការមួយចំនួន ដូចជា៖ ធ្វើកំណត់ហេតុជាមួយតំណាងសហគ្រាសឱ្យធ្វើការកែសម្រួលឡើងវិញនូវការចេញវិក្កយបត្រឱ្យបានត្រឹមត្រូវតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងមិនអនុញ្ញាតឱ្យឥណទានអាករលើធាតុចូល ឬព្យួរការស្នើសុំបង្វិលសងក្នុងករណីមិនអនុវត្តតាមវិធានវិក្កយបត្រ។

**៤.៧. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធៈ** ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធ ជាភារកិច្ចរបស់មន្រ្តីពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសមួយចំនួនបានប្រកាសពន្ធមិនត្រឹមត្រូវ និងសមស្រប ដូចជា គណនាពន្ធលើប្រាក់បៀវត្សរ៍មិនត្រឹមត្រូវ មិនបានប្រកាសពន្ធកាត់ទុកលើសេវា ប្រកាសពន្ធកាត់ទុកលើថ្លៃឈ្នួលទីតាំងមិនស្របនឹងទិន្នានុប្បវត្តិទិញប្រកាសចំណូលថេរ ប្រកាសថ្លៃឈ្នួលទីតាំងទាប ឬមិនប្រកាសឈ្នួលទីតាំង ប្រកាសបៀវត្សរ៍ជនបរទេសទាបមិនបង្ហាញមូលដ្ឋានគិតអាករបំភ្លឺសាធារណៈ មិនបានប្រកាសអាករលើតម្លៃបន្ថែម និងមិនប្រកាសចំណាយទឹកស្អាត អគ្គិសនី និងហ្គាសចំអិនអាហារ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺបន្ថែមថា ប្រព័ន្ធ

ពន្ធដារបែបស្វ័យប្រកាស អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធនៅធនាគារពាណិជ្ជ ហើយបន្ទាប់ពីបង់ពន្ធរួច អ្នកជាប់ពន្ធយកលិខិតប្រកាសមកដាក់នៅរដ្ឋបាលសារពើពន្ធដោយខ្លួនឯង។ ដោយមានការណែនាំជាប់ជាប្រចាំ និងតាមរយៈសិក្ខាសាលាផ្សព្វផ្សាយដល់អ្នកជាប់ពន្ធឱ្យមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីកាតព្វកិច្ចសារពើពន្ធ ការអនុវត្តច្បាប់ពន្ធដារ និងការកាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវ ជាក់ស្តែងសហគ្រាសមួយចំនួនបានទទួលយកការណែនាំ និងធ្វើការកែតម្រូវបានប្រសើរជាងមុន។ ម្យ៉ាងវិញទៀត អ្នកជាប់ពន្ធតែងតែសម្រុកមកដាក់លិខិតប្រកាសពន្ធប្រចាំខែ នៅថ្ងៃផុតកំណត់ការទទួលលិខិតប្រកាសដែលធ្វើឱ្យមានភាពកកស្ទះ នាំឱ្យមន្រ្តីទទួលលិខិតប្រកាសមិនអាចពិនិត្យទិន្នន័យលើលិខិតប្រកាសពន្ធរបស់អ្នកជាប់ពន្ធបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ប៉ុន្តែបន្ទាប់ពីទទួលលិខិតប្រកាសរួចហើយ មន្រ្តីទទួលបន្ទុកលិខិតប្រកាសបានធ្វើការត្រួតពិនិត្យតាមក្រោយ ករណីលិខិតប្រកាសពន្ធណាដែលមានភាពមិនប្រក្រតី មន្រ្តីទទួលបន្ទុកបានអញ្ជើញតំណាងមកធ្វើការណែនាំឱ្យធ្វើការកែតម្រូវលិខិតប្រកាសឡើងវិញ និងដាក់កម្មវិធីធ្វើសវនកម្មមានកម្រិត។

៤.៨. **ការប្រមូលពន្ធអចលនទ្រព្យៈ** គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបានតម្រូវឱ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។ ការអនុវត្តប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិតនៅឡើយ ដោយសារអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនទៀតបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានបំភ្លឺថា អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួនដូចជា កង្វះខាតទិន្នន័យអចលនទ្រព្យ និងខ្វះមន្ត្រីដើម្បីចុះត្រួតពិនិត្យគ្រប់អចលនទ្រព្យ។ ម្ចាស់អចនលទ្រព្យមួយចំនួននៅតែមិនយកចិត្តទុកដាក់ ឬរឹងរូសក្នុងការបំពេញកាតព្វកិច្ចពន្ធ ប៉ុន្តែម្ចាស់អចលនទ្រព្យពុំអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យនោះបានឡើយ បើសិនអចលនទ្រព្យនោះនៅពុំទាន់បានបង់ពន្ធលើអចលនទ្រព្យ។ អចលនទ្រព្យមួយចំនួនមិនជាប់ពន្ធ (តម្លៃក្រោម១០០លានរៀល) និងមួយចំនួនបានចុះបញ្ជីស្ទួន ហើយប្រព័ន្ធគ្រប់គ្រងអចលនទ្រព្យពុំបានបង្ហាញទិន្នន័យលម្អិតអំពីអចលនទ្រព្យទាំងនោះ។ ប៉ុន្តែ អគ្គនាយកដ្ឋានពន្ធដារមិនបានទុកបញ្ហានេះបណ្តែតបណ្តោយនោះទេ គឺបានបង្កើតក្រុមការងារចុះផ្តល់សេវាចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពតាមរយៈការធ្វើអង្កេតអចលនទ្រព្យនៅរាជធានី និងតាមបណ្តាខេត្ត។ កត្តានេះអាចជួយរដ្ឋបាលសារពើពន្ធងាយស្រួលក្នុងការត្រួតពិនិត្យ និងជំរុញការបំពេញកាតព្វកិច្ចពន្ធរបស់ម្ចាស់អចលនទ្រព្យបានគ្រប់គ្នា។

៤.៩. **ការកត់ត្រាចំណូលថវិការដ្ឋៈ** បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកបត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានរៀបចំបញ្ជូនទៅឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកបត្រ ឬដីកាចំណូលរបស់អាណាប័កនៅឡើយ ដោយសារក្រសួង ស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកបត្រចំណូលមកឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ។ ករណីនេះ កន្លងមក អគ្គនាយកដ្ឋានរតនាគារជាតិ បានខិតខំជំរុញណែនាំដល់គ្រប់ក្រសួងស្ថាប័ន និងអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធក្នុងការធ្វើសលាកបត្រចំណូលថវិការដ្ឋតាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល ប្រព័ន្ធទំនាក់ទំនងតេឡេក្រាម(Telegram) និងបានរៀបចំបញ្ជូនលិខិតស្នើសុំទៅសាមីក្រសួងស្ថាប័នផ្ទាល់ ដើម្បីឱ្យការកត់ត្រាចំណូលថវិការដ្ឋមានភាពត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលា។ ជាក់ស្តែង ក្នុងឆ្នាំថវិកា២០១៧ អគ្គនាយកដ្ឋានរតនាគារជាតិ បាន

រៀបចំលិខិតដើម្បីស្នើសុំជំរុញការងារខាងលើចំនួន៣លើក ក្នុងនោះ៖ (១) លិខិតលេខ១០៥៨៣ សហវ.អរតន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៦ ស្នើសុំទៅគ្រប់ក្រសួង ស្ថាប័ន (២) លិខិតលេខ៨៧៧៣ សហវ.អរតន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ ស្នើសុំទៅក្រសួងការពារជាតិ និង(៣)លិខិតលេខ០៥១ សហវ.អរតន ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្នើសុំទៅក្រសួងការពារជាតិ។ ជាលទ្ធផល ក្រសួង ស្ថាប័នភាគច្រើនបាន ខិតខំព្យាយាមអនុវត្តបានត្រឹមត្រូវ ប៉ុន្តែក្រសួងស្ថាប័នមួយចំនួនទៀតនៅពុំទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ តាមច្បាប់កំណត់នៅឡើយ។ ជាក់ស្តែង ការកត់ត្រាចំណូលមិនមែនសារពើពន្ធដែលមិនមានដីកាចំណូល ក្នុងឆ្នាំថវិកា២០១៧ ដែលមានចំនួន ៦ ៤៥៧,៥លានរៀល គឺមានការថយចុះប្រមាណ ៣៥ ៦៤៨,១ លានរៀល ធៀបនឹងឆ្នាំថវិកា២០១៦ ដែលមានទឹកប្រាក់ចំនួន ៤២ ១០៥,៦ លានរៀល។ បើពិនិត្យតួលេខ កត់ត្រាចំណូលមិនមែនសារពើពន្ធដែលមិនមានដីកាចំណូលក្នុងរយៈពេល៣ឆ្នាំចុងក្រោយ ឃើញមានវឌ្ឍន ភាពល្អប្រសើរ ដូចតទៅ៖ (១) ឆ្នាំ២០១៧ មានចំនួន៦ ៤៥៧,៥លានរៀល (២) ឆ្នាំ២០១៦ មានចំនួន ៤២ ១០៥,៦លានរៀល និង(៣) ឆ្នាំ២០១៥ មានចំនួន ១ ០០៦ ៩៧២,៨លានរៀល។

**៤.១០. ការទូទាត់ និងការកត់ត្រាចំណាយៈ** ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គ នាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់មួយចំនួនតូចទៅអគ្គនាយកដ្ឋានរតនាគារ ជាតិនៅតែមានភាពយឺតយ៉ាវ ពុំទាន់ពេលវេលាដែលបង្កឱ្យមានការលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។ អាណត្តិបើកប្រាក់ទាំងនោះ គឺមានអាណត្តិនិយ័តកម្មមួយចំនួន (អាណត្តិទូទាត់ប្រាក់បុរេប្រទាន និងអាណត្តិ ទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទាន) ដែលចាំបាច់ត្រូវទូទាត់ជម្រះបញ្ជីក្នុងឆ្នាំថវិកា២០១៧ ដើម្បីបិទបញ្ជីដោយ កត់ត្រាចំណាយថវិកាឱ្យបានពេញលេញ និងបង្ការកុំឱ្យមានការលំបាកច្រើនដល់កិច្ចទូទាត់ជម្រះបញ្ជីនៅឆ្នាំ បន្តបន្ទាប់។ ម្យ៉ាងទៀតរយៈពេលនេះគឺស្ថិតនៅក្នុងរយៈពេលបំពេញបន្ថែមសម្រាប់ប្រតិបត្តិការនិយ័តកម្មនៃ រតនាគារ។ បន្ថែមពីលើនេះ ឆ្នាំថវិកា២០១៧ មានក្រសួងស្ថាប័នសរុបចំនួន ៣៦ ដែលបានអនុវត្តថវិកា កម្មវិធីពេញលេញ មានការអនុវត្តចំណាយថវិកានាដើមឆ្នាំថវិកាមានភាពយឺតយ៉ាវ។ ដូច្នេះក្នុងឆ្នាំថវិកា ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកំណត់កាលបរិច្ឆេទបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ នៅ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមវេលាម៉ោង១៧ និង៣០នាទី នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ដើម្បី សម្រួលដល់ការទូទាត់ចំណាយចាំបាច់ និងការទូទាត់ជម្រះបញ្ជីសម្រាប់ប្រតិបត្តិការចំណាយក្នុងឆ្នាំថវិកា ២០១៨ និងដើម្បីជៀសវាងការបង្គរបន្ទុកចំណាយទៅឆ្នាំថវិកា២០១៨ និងឆ្នាំបន្តបន្ទាប់។

**៤.១១. ការត្រួតពិនិត្យភាពត្រឹមត្រូវនៃអាណត្តិបើកប្រាក់៖** ដើម្បីធានាបាននូវការទទួលខុសត្រូវក្នុង ការអនុវត្តចំណាយថវិការដ្ឋ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាគណនេយ្យករសាធារណៈ មានតួនាទី យ៉ាងសំខាន់ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ។ ដើម្បីអនុវត្តតួនាទីនេះបានគត់មុត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីលិខិតយុត្តិការភ្ជាប់អាណត្តិ បើកប្រាក់សម្រាប់ការទូទាត់ចំណាយថវិកាដែលអនុវត្តតាមនីតិវិធីលទ្ធកម្ម សាធារណៈ តម្រូវឱ្យក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវភ្ជាប់លិខិតយុត្តិ ការជាមួយនឹងអាណត្តិបើកប្រាក់សម្រាប់ទូទាត់ចំណាយ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ដូចជា៖ កិច្ចសន្យាលទ្ធកម្ម ដែលមានពន្ធប្រថាប់ត្រា និងប័ណ្ណប៉ាតង់ដែលប្រភេទអាជីវកម្មត្រូវស្របតាមការផ្គត់ផ្គង់ ជាដើម។ល។ តាមការធ្វើតេស្តលើអាណត្តិបើកប្រាក់មួយចំនួនរបស់ក្រសួងមួយចំនួន ដែលទទួលបាន ការយល់ព្រមទូទាត់ដោយអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អាណត្តិបើក

ប្រាក់មួយចំនួន មិនបានភ្ជាប់នូវឯកសារគាំទ្រត្រឹមត្រូវ ដូចជា ប្រភេទអាជីវកម្មរបស់អ្នកផ្គត់ផ្គង់មិនសមស្រប តាមកម្មវត្ថុនៃការចំណាយ (ប្រភេទអាជីវកម្មមិនត្រូវតាមការផ្គត់ផ្គង់) កិច្ចសន្យាលទ្ធកម្មប្រថាប់ត្រាក្រោយកាលបរិច្ឆេទដែលអគ្គនាយកដ្ឋានរតនាគារជាតិយល់ព្រមទូទាត់។ ការខកខានរបស់អគ្គនាយកដ្ឋានរតនាគារជាតិលើការត្រួតពិនិត្យភាពត្រឹមត្រូវនៃការអនុវត្តចំណាយថវិការដ្ឋ ធ្វើឱ្យការទូទាត់អាណត្តិបើកប្រាក់មិនបានត្រឹមត្រូវតាមគោលការណ៍គណនេយ្យ។ ឆ្លើយតបទៅនឹងបញ្ហាខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា អាស្រ័យដោយការយកចិត្តទុកដាក់លើវិធានការពង្រឹងប្រសិទ្ធភាពចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឥណទានថវិកាដែលសន្សំបានត្រូវបានលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នយកទៅបង្កើនការចំណាយចាំបាច់មួយចំនួន ដែលភាគច្រើនអនុវត្តនៅចុងឆ្នាំ ដែលជាហេតុធ្វើឱ្យនីតិវិធី និងបែបបទការទូទាត់អូសបន្លាយឆ្លងឆ្នាំ។ ក្នុងន័យនេះ ដើម្បីឱ្យប្រតិបត្តិការចំណាយបញ្ចប់មិនឱ្យឆ្លងឆ្នាំ ក្រសួង ស្ថាប័នមួយចំនួនត្រូវបានអនុញ្ញាតឱ្យបំពេញឯកសារលិខិតយុត្តិការភ្ជាប់ដែលនៅខ្វះចន្លោះតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុតាមក្រោយ។

**៤.១២.ការយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធ:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៧ ដោយបញ្ជាក់ថា ការិយបរិច្ឆេទនៃឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ (មាត្រា១១នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ) និងប្រាក់ចំណូលទាំងអស់ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទីII និងមាត្រា១០៦ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ ដូចនេះប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ជាកំហិត។ តាមការធ្វើសវនកម្មអាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (នាយកដ្ឋានចំណូលសាធារណៈ) មានសមតុល្យតួលេខចំណូលមិនមែនសារពើពន្ធមួយចំនួន (រដ្ឋបាលកណ្តាល) នៅសល់ចុងឆ្នាំ២០១៧ មិនទាន់បានបង្វែរចូលថវិការដ្ឋនៅឡើយទេ។

**៤.១៣. ការធ្វើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:** អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា "ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើរបាយការណ៍លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។ សារាចរណែនាំស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី២៤ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មរបស់ខ្លួនប្រចាំត្រីមាស ឆមាស និងឆ្នាំ (តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់នៅរៀងរាល់ចុងសប្តាហ៍ទី១ ខែមេសា ខែកក្កដា ខែតុលា និងខែមករា។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៧ មានសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈសរុបចំនួន៣៧ ក្នុងនោះសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈចំនួន៣៥បានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ ប៉ុន្តែនៅសល់ចំនួន០២ អង្គភាពទៀតនៅមិនទាន់បានធ្វើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំមកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៅឡើយ។

**៤.១៤. ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ:** រដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់

ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

**៤.១៥. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋៈ** រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៧ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់ត្រូវបានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ បានបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែង ពុះពាររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវស្របតាមសភាពការណ៍ជាក់ស្តែង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពរីកចម្រើន និងគត់មត់ពីមួយឆ្នាំទៅមួយឆ្នាំ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ សមិទ្ធផលទាំងនេះ មានប្រសិទ្ធភាពបំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ និងបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ និងឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការបន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច និងការធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការកាត់បន្ថយភាពក្រីក្រ និងបានផ្តល់នូវមធ្យោបាយ និងធនធានសមស្របដល់ក្រសួង ស្ថាប័ន ជាពិសេសការបង្កើនល្បឿននៃការអភិវឌ្ឍ ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជាច្រើនទៀតរបស់ជាតិ និងប្រជាជន រួមមានការបន្តតម្លើងបៀវត្សរ៍ជូនមន្ត្រីរាជការទូទៅ ការបន្តគាំទ្រការវិនិយោគចាំបាច់នានា ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយឈរលើគោលការណ៍ប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជន៍ និងទាំងក្នុងកម្រិតប្រតិបត្តិការ និងបច្ចេកទេស។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់ចំណូល ចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួង ស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។